# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែសីហា លេខ ៨
ព. ស. ២៤៩៤ – គ. ស. ១៩៥១

11·19

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — *ទំព័រ*

ពុទ្ធសាសនានឹងគ្រីស្ដសាសនា (សន្និសីទ លោកវេជ្ជបណ្ឌិតមីគួត់) (តមក) ... លោកប៉ាយ-ប៊ុក .......... ៥៦៤
ពន្លឺអាស៊ីទ្វីប (តមក) ........... លោកប៉ាយ-ប៊ុក .......... ៥៧០
យភាវិសធម្មកថា ................ ព្រះគ្រូមុនីសោភ័ណ សេខ-នាង.. ៥៧៥

*ផ្នែកអក្សរសាស្ត្រ*

ការបណ្ដុះនិស្ស័យ (តមក) ........ ព្រះមហាឧត្ដមវិជ្ជា ប៉ុង-ម៉ម .... ៥៨៤
អីឡេណា-ស៊ីម្ប៉ាណា (តមក) ..... លោកផេង-ជ្រីវ .......... ៥៩៣
រឿងសាមកុក (តមក) ........... ឧកញ៉ា ង្វ-កន .......... ៦០១
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).. ឧកញ៉ា ឈឹម-ក្រសេម ..... ៦១៤
រឿងអារក្សថ្លែងរឿងម្ភៃប្រាំ (តមក) .... លោកសាង-សាភ័ត ....... ៦១៩

*កំណត់នឹងប្រវត្តិការណ៍*

ដំណើរមកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិត
គុណបាលបិយសេន ម៉ាល៉ាល័ះសេកេរះ (តមក) ពុទ្ធសាសនបណ្ឌិត្យ ......... ៦២៨

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៤៥ រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


### PARTIE RELIGIEUSE

| | | Pages |
|---|---|---|
| Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite) | *M. RAY-BUC* | 564 |
| La Lumière de l'Asie (suite) | *M. RAY-BUC* | 570 |
| Gharàvàsa dhammakathà | *PREAH KROU MONISOBHANA SEK-NEANG* | 575 |

### PARTIE LITTERAIRE

| | | |
|---|---|---|
| Education morale (suite) | *Prah Maha PEUNG-PAM* | 584 |
| Histoire d'Héléna-Simiana (suite) | *M. PHENG-CHRIEU* | 593 |
| Histoire de SAMKOK (suite) | *Oknha NOU-KAN* | 601 |
| Histoire du Royaume du Cambodge (suite | *Oknha CHHIM-KRASEM* | 614 |
| Les vingt-cinq récits du mauvais génie «Conte indien» (suite) | *M. SANG-SAVATH* | 619 |

### NOTES ET CHRONIQUES

| | | |
|---|---|---|
| Voyage au Cambodge du Dr.G.P. Malalasekera, Président du Centre mondial des Bouddhistes de Ceylan (suite | *Institut Bouddhique* | 628 |


Prix d'abonnement annuel comprenant 12 numéros: 145$00

# ប្រទេសកម្ពុជា ចូលជាសមាជិក

# នៃពុទ្ធិកសមាគមពិភពលោក នៅលង្កាទ្វីប

# ចាប់តាំងពីឆ្នាំ ១៩៥១ នេះតទៅ

កាលនៅថ្ងៃទី ២៥ ខែឧសភាឆ្នាំ ១៩៥១ ពុទ្ធិកសមាគមពិភពលោក បានធ្វើមហាសន្និបាត ដោយការអញ្ជើញប្រទេសកាន់ពុទ្ធសាសនាទាំង ៣២, មានអ្នកតំណាង ១៣២ នាក់ទៅជួបជុំ ៗ ក្នុងមហាសន្និបាតនោះ គណៈប្រតិភូខាងព្រះពុទ្ធសាសនានៃប្រទេសខ្មែរយើង មានសម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកជាប្រធាន បានសុំឲ្យប្រទេសកម្ពុជាចូលជាសមាជិក នៃពុទ្ធិកសមាគមពិភពលោក នៅលង្កាទ្វីប ។ ឯប្រាក់មួយពាន់រូពី (រូពិយ)ដែលប្រទេសជាសមាជិកត្រូវបង់រៀងរាល់ឆ្នាំ ដើម្បីចំណាយក្នុងការផ្សាយពុទ្ធសាសនាទៅក្នុងសាកលលោក នោះប្រទេសកម្ពុ-ជាទីងផ្ញើទៅជូនពុទ្ធិកសមាគមពិភពលោកក្នុងឆ្នាំ ១៩៥១ នេះ ។

ពុទ្ធសាសនបណ្ឌិត្យ

## ពុទ្ធសាសនា និង គ្រិស្តសាសនា

# សន្និសីទលោកវេជ្ជបណ្ឌិត មីគូត៍

លោក រ៉ាយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីទស្សនាវដ្ដី "ហ្វ្រង់អាស៊ី" ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

---

តាមលទ្ធិមហាយាន, យើងអាចស្វែងរកឃើញនូវឧត្ដមគតិព្រះពោធិសត្វ ដែលព្រះអង្គទ្រង់ទេសនាចំពោះសីលធម៌ខាងព្រះពុទ្ធសាសនា អាចវិវត្តន៍ទៅកាន់ព្រហ្មវិហារដ៏ជាថ្នាក់ខ្ពស់បំផុត ។ សាវកមិនបានស្វែងរកព្រះនិព្វានចំពោះអាត្មា ត្រឡប់ទៅអធិដ្ឋានក្នុងចិត្តថា នឹងជួយស្រោចស្រង់សត្វលោក ប្រកាសបំណងព្រះពោធិសត្វដែលមានអត្ថបទមួយសំដែងដោយក្បោះក្បាយថា : "តើនៅ[១] ក្នុងចក្រវាឡនេះ, ខ្ញុំអាចតាំងខ្លួនជាអ្នកស្រោចស្រង់សត្វលោកបានឬ? តើខ្ញុំអាចយល់បានថាពពួកសត្វលោកនេះជាមាតា, ជាបិតា, ជាបងស្រី, ជាបងប្រុសរបស់ខ្ញុំ ហើយខ្ញុំអាចជាមគ្គុទ្ទេសក៍នៃសត្វទាំងអស់ ឲ្យឆ្លងកាត់មហាសាគរទៅកាន់កោះគឺនិព្វានបានឬ? ។ តាំងពីនោះមក ព្រះពោធិសត្វទ្រង់បានប្រព្រឹត្តនូវគុណធម៌ដ៏ឧត្ដមតាមថ្នាក់តាមជាន់ ដើម្បីនឹងឲ្យព្រះអង្គទ្រង់ផុតចាកវដ្ដសង្សារទៅកាន់ព្រះនិព្វាន ។ តែក្នុងពេលដែលព្រះអង្គទ្រង់

---

១ ពោធិចរិយាវតារ ។

អន្ទោលយកកំណើតក្នុងភព ទ្រង់តែងមានទុកចិត្តជានិរន្តរកាលទៅកាន់សត្វលោកដែលរងទុក្ខលំបាក ទ្រង់មានព្រះទ័យមេត្តាករុណាចំពោះសព្វសត្វ ៗ ដោយទ្រង់ខំព្យាយាមបំពេញពុទ្ធការកធម៌ជាច្រើនជាតិ ទ្រង់បានសម្រេចនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ហើយទ្រង់ក៏លះបង់ប្រយោជន៍ផ្ទាល់ព្រះអង្គ ដើម្បីប្រយោជន៍សត្វក្នុងសាកលលោក, ទ្រង់ស្ថិតនៅក្នុងវដ្តសង្សារ ដើម្បីនឹងជួយស្រោចស្រង់សត្វឲ្យផុតពាកទុក្ខ ៗ ឧត្តមគតិនៃព្រះមហាបុរសប្រកបដោយវីរភាព, មានពណ៌នានៅក្នុងអត្ថបទជាច្រើន ៗ ចំណែកខាងគម្ពីរ "សិក្សាសមុច្ច័យ"ពោលថា: ត្រូវតែអាត្មាទទួលកាន់ការខានមិនបានចំពោះភារៈ គឺទុក្ខលំបាករបស់សត្វលោក ៗ ដោយមិនបានគិតត្រឹមតែការរួចផុតស្រឡះពីវដ្តសង្សារចំពោះអាត្មាទេ អាត្មាមានសទ្ធុះចិត្តយ៉ាងមាំ ចង់ដឹកនាំសត្វឲ្យទៅកាន់ព្រះប្រាជ្ញាញាណនៃព្រះសម្មាសម្ពុទ្ធទៀតផង ៗ ត្រូវតែអាត្មាទទួលទុក្ខលំបាករបស់សត្វលោកទាំងអស់; អាត្មាអាចប្រើរូបនេះ ឲ្យទទួលនូវទុក្ខរបស់ប្រជាករទាំងអស់ ដើម្បីនឹងធ្វើលោកឲ្យផុតពាកទុក្ខ, បានជាអាត្មាមានចិត្តប្រាថ្នាចង់ត្រាស់ជាពុទ្ធភូមិ" ៗ តើគេអាចយល់ឃើញបាន តាមព្រះបរមពុទ្ធោវាទខាងលើនេះនូវសីលធម៌ដ៏វិសេស ដែលកើតឡើងដោយបហានធម៌ ដូចគេបានឃើញនូវការប្រៀនប្រដៅខាងសីលធម៌នៃព្រះគ្រិស្តដែរឬ? រឿងដែលពណ៌នានេះមិនគឺពលីកម្មដែលមានន័យខាង

ព្រះគ្រិស្ត ក្នុងមហាយញ្ញ (Rédemption; ដើម្បីនឹងធ្វើឲ្យមនុស្សទាំងអស់ក្នុងលោកបានរួចផុតចាកទុក្ខទាំងពួងឬ? ។

អ្នកឃើញថា: សីលធម៌ខាងព្រះពុទ្ធសាសនា គឺមិនមែនសីលធម៌ប្រកបដោយអកម្មនិងប្រាជ្ញាសាមញ្ញ ដែលគេតែងពោលជាញឹកញយ ដោយគ្មានយល់នូវអត្ថរសនិងទម្រង់នៃសីលធម៌នោះឡើយ ។ សីលធម៌នោះ មិនមែនមានសភាពអន់ទន់ខ្សោយជាងការប្រៀនប្រដៅខាងគ្រិស្តសាសនានោះទេ ។ តែគេមិនដែលបានឃើញខាងការប្រៀនប្រដៅនៃព្រះពុទ្ធត្រង់ការប្រើទារុណកម្ម, បញ្ចេញនូវសេចក្តីក្រោធក្តាម ៗ គំនុំព្យាបាទហើយនិងពោលពាក្យផរុសវាចា ដែលគេទុកជាអត្ថពេកាសក្នុងការប្រព្រឹត្តនូវកំណាចដោយផ្ទាល់ខ្លួនឬប្រើគ្នា ដែលមិនគួរនឹងយកមកពណ៌នានៅទីនេះ[1] ។ ការសិក្សានៃព្រះពុទ្ធសាសនាឲ្យកើតសន្តិភាពនិងវិមុត្តិភាព ដែលខាងគម្ពីរគ្រិស្តសាសនាមិនដែលមានពោលសោះ ។

---

១ ខ្ញុំចង់ពោលអំពីពាក្យផរុសវាទសម្បើមអស្ចារ្យនៃព្រះយេស៊ូ ដែលពណ៌នាចំពោះជនស៊ីហ្វ ។ ពាក្យផរុសវាទនោះ គឺជាលេសមួយក្នុងចំណោមលេសទាំងអស់ដែលនាំឲ្យលទ្ធិអង់សេមីទិស្ម (លទ្ធិដែលយល់ផ្ទុយគ្នាពីយោបល់ជាតិស៊ីហ្វឬហេប្រឺ) ដែលនាំឲ្យវិនាសដោយធ្វើឲ្យលោហិតហូរក្នុងពិភពលោកមានមហាសង្គ្រាមលើកក្រោយជាដើម ។ មានអ្នកនិពន្ធមានប្រាជ្ញាម្នាក់ បានពោលក្នុងសៀវភៅមួយដែលមានសង្ឃាតុញ្ញពីចេរសភាកាតូលិក បានបញ្ជាក់អំពីការធ្វើឃាតកម្មពួកស៊ីហ្វនៅទារុណកម្មស្ថាន (Campd'extermination) នៃពួកណាស៊ី (nagi) ពន្យល់ថា ទារុណកម្មនៃជាតិស៊ីហ្វនេះអាទិទេវបញ្ញត្តិ អ្នកនិពន្ធនេះមិនបានពោលចំពោះអាទិទេវបំណងចំពោះអ្នកពិឃាតឯទៀត ( ស.អ៊ីសាអាក់អ្នកនិពន្ធរឿង " សេស៊ីសនិងអ៊ីស្រាអែល " បោះពុម្ពនៅបណ្ណាគារអាបាំងម៉ីសែលប៉ារីស ) ។

មានន័យមួយដែលធ្វើឲ្យសីលធម៌ខាងព្រះពុទ្ធសាសនា មានវឌ្ឍនធម៌ឲ្យពិតប្រាកដឡើង គឺលទ្ធិអហឹសភាព (non violence), សិក្ខាបទទី ១ នៃវិន័យខាងសាសនាស៊ុយដាអ៊ិកគឺដូចគ្នានឹងសិក្ខាបទទី ១ ខាងពុទ្ធ-បញ្ញត្តិដែរ : "ឯងមិនត្រូវសំឡាប់សត្វទេ" ។ ព្រះគ្រិស្តបានពន្យល់អំពីតម្លៃនៃសិក្ខាបទនេះ ហើយបានបញ្ចូលគ្រិស្តោវាទឯទៀតជាច្រើនដែលពណ៌នាអំពីបាដិហារ្យព្រះគ្រិស្តដោយអំណាចនៃព្រហ្មវិហារ កុំឲ្យតបតនឹងការឃោរឃៅអ្នកដទៃ : "បើគេវាយថ្ពាល់ស្តាំ ត្រូវបង្ហាញថ្ពាល់ស្តាំឲ្យគេវាយទៀត ត្រូវឲ្យស្រឡាញ់បច្ចាមិត្រ" ។ ពិតតលោកបានប្រកាសរឿងនេះប្រាំមួយសតវត្សមកហើយមុនព្រះគ្រិស្ត ។ យើងបានយកឧទាហរណ៍ជាច្រើនមកពណ៌នា, យើងនឹងអាចយកឧទាហរណ៍ឯទៀតមកសំដែងនៅទីនេះទៀតក៏បាន, គេបានឃើញជាពិសេសតាមទម្រង់ផ្សេងៗ នូវគម្ពីរជាតកគ្រប់ទំព័រ គេបានពណ៌នាអំពីរឿងរ៉ាវនៃសីលធម៌ខាងពុទ្ធសាសនាដោយគ្រោះគ្រាយ ។

ព្រះពុទ្ធសាសនាបានរក្សានូវការសិក្សាខាងលើនេះ ទុកជាការសិក្សាសំខាន់ ៗ សម័យបច្ចុប្បន្នដូចជាពីសម័យអតីតដែរ បើមានសង្គមណាមានអន្តេកាសយ៉ាងណាក៏ដោយ ព្រះពុទ្ធសាសនាទុកការពិឃាតនេះ ជាកិច្ចលាមកបំផុត ។ សង្គ្រាមក្នុងលោក, ការឈ្លក់ចិត្តទៅក្នុងនយោបាយ ឬមនោសញ្ចេតនា, កិច្ចដែលត្រូវការពារខ្លួនៗឯង និងការ

ជំនុំជំរះសាលាតុលាការ មិនអាចឃាត់មនុស្សមិនឲ្យសម្លាប់គ្នា ឬបន្ថយនូវការពិឃាតឲ្យមានសភាពថយចុះសោះឡើយ ហើយការហាមមិនឲ្យពិឃាតនោះមិនមែនមានព្រំដែនត្រឹមតែមនុស្សទេ គឺវាតន័យនោះដល់សត្វលោកទាំងអស់រហូតដល់សាមញ្ញសត្វ ៗ ពួកពុទ្ធមាមកជនពិត ៗ មិនទៅបរបាញ់ទេ, មិនសម្លាប់សត្វសោះឡើយ ហើយស្វែងរកឧបាយមិនធ្វើទុក្ខលំបាកដល់សត្វដែលមានជីវិតសោះឡើយ ៗ

ឯពួកគ្រិស្តសាសនិកជនអនុម័តថាសិក្ខាបទ "មិនពិឃាតសត្វ" ទៅជាទោសវិញ ទាល់តែសិក្ខាបទនោះរលុបរលាយ គ្មានជាអវសាន ៗ ពួកនិកាយខាងគ្រិស្តសាសនាសម័យបច្ចុប្បន្ន យល់ថាសិក្ខាបទនេះមានន័យផ្ទុយគ្នានឹងគ្រិស្តរាទ ៗ ដោយវិចារណញាណខាងនយោបាយពួកនិកាយនេះបានបញ្ជាក់ថា ការពិឃាតប្រកបដោយសមូហភាពជាកិច្ចដ៏ប្រសើរ ដោយយល់ថាលទ្ធិបែបនេះគេទុកជា "សង្គ្រាមប្រកបដោយសច្ចៈ" ៗ និកាយនេះ បានសរសើរនូវកិត្តិនាមនៃពួកយោធា បានទុកថាពួកនេះ ដែលអនិច្ចកម្មកងទ័ពសមរភូមិ ជាទុក្ករបុគ្គលដ៏វិសេស, យកគ្រឿងសស្ត្រាវុធសម្រាប់ពិឃាតជាប្រធាន, និកាយនេះ បានយកអន្តរាគាសប្រកបដោយមនុស្សភាពទៅកាន់សង្គ្រាម ដោយយកប្រទេសដទៃ ធ្វើជាអាណានិគម ឬសង្គ្រាមដោយប្រើលទ្ធកម្មខាងអាវុធ ៗ កិច្ចនេះនាំឲ្យរំជួលជាខ្លាំងខាងផ្លូវប្រាជ្ញា, កងសម័យបច្ចុប្បន្ន គេទុកសង្គ្រាម

ថាជាកិច្ចរវល់ដ៏សំខាន់ចំពោះប្រជារាស្ត្រ ដែលគ្មានសំឡេងណាមួយហ៊ានបញ្ចេញចំពោះអ្នកតំណាងជាផ្លូវការមួយខាងគ្រិស្តសាសនា ដើម្បីនឹងពោលពាក្យបន្ទោសចំពោះមុខពេញលក្ខណៈ ពីរឿងការសង្គ្រាមទាំងអស់ ក្នុងសាកលលោកព្រមទាំងអ្នកដែលបង្កនូវសង្គ្រាមទាំងនោះបានឡើយ បើទុកជាអ្នកទាំងនោះបានឲ្យអន្តរោកាសយ៉ាងណាក៏ដោយ ។

តែដែលនាំឲ្យពុទ្ធមាមកជនទាំងឡាយរំជួលជាខ្លាំង គឺសង្គ្រាមខាងសាសនា ។ ព្រោះហេតុដូចម្តេច បានជាគ្រិស្តសាសនិកជនពិឃាតគ្នាទៅវិញទៅមក ដោយអាងថាអំពើឧក្រិដ្ឋនេះ គឺធ្វើទៅតាមវិចារណញ្ញាណខាងសាសនា, ហើយក្នុងបរមនាមនៃព្រះអាទិទេព? ។ សង្គ្រាមសាសនា ការនាំកងទ័ពទៅច្បាំងដណ្តើមយកបូជនីយដ្ឋានព្រះគ្រិស្តនៅទីក្រុងសេរុយសាលិម (croisades) និងយកក្រុមតុលាការខាងគ្រិស្តសាសនាឬគ្រិស្តសភា (inquisitions) នោះ បើតាមសេចក្តីយល់ខាងពួកបូព៌ាជាតិ ថាជាការប្រតិបត្តិផ្ទុយនឹងព្រះគ្រិស្តនឹងគ្រិស្តោវាទពិតៗ ។ ចំណែកខាងប្រទេសដែលកាន់ព្រះពុទ្ធសាសនា មិនដែលបានជួបប្រទះនូវសេចក្តីវង្វេងកាន់ច្រឡំបែបនេះសោះឡើយ ។

(មាឧក)

ពន្លឺអាស៊ី

# វគ្គទី ៣

La Lumière de l'Asie

*លោក ស៊ីរ-អេតវ៉ឹន អារណូលត៍ តែង*

## លោកប៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

**(តមក)**

---

ក្នុងប៉ុន្មានឆ្នាំនេះ ព្រះបាទសុទ្ធោទនៈ ទ្រង់មានព្រះទ័យព្រួយជាអនេកប្បការ ព្រោះទ្រង់ធ្លាប់ព្រះសណ្ដាប់នូវព្រះសូរសៀងព្រមទាំងទតនូវព្រះរូបនៃព្រះរាជឱរសរបស់ព្រះអង្គ ក្នុងចំណោមនៃមន្ត្រីធំៗក្នុងព្រះរាជវង្សានុវង្ស ។ ចំណែកព្រះនាងយសោធរាទ្រង់ព្រួយព្រះរាជហឫទ័យពន់ពេក ដោយព្រះនាងឃ្លាតចាកព្រះស្វាមីជាម្ចាស់ជាច្រើនឆ្នាំ ហើយតាំងពីនោះមក ព្រះនាងមិនដែលបានក្រេបនូវឱជារសនៃសេចក្ដីសប្បាយក្នុងជីវភាពសោះឡើយ ។ ដូនកាលមានឮដំណឹងថាមានពួកជិះអូដ្ឋក្នុងវាលខ្សាច់នឹងពួកពាណិជដែលស្វែងលាភឆ្ងាយពីផ្លូវធម្មតា ពោលអំពីឥសីម្នាក់ដែលស្ថិតនៅស្រុកឆ្ងាយដាច់សង្វែង ។ ព្រះរាជបម្រើនៃព្រះមហាក្សត្របានទៅស្វែងរកគ្រប់តំបន់ ហើយត្រឡប់មកវិញប្រាប់ថា ឃើញតែតាបសឥសីជាច្រើនស្ថិតនៅតែឯកឯងគ្មានគេហដ្ឋាន; តែគេមិនបានដំណឹងពីព្រះរាជឱរស ដែលជាទីគោរពនៃព្រះរាជវង្សានុវង្សក្នុង

ព្រះបរមរាជវាំងក្រុងកបិលវត្ថុ, ជាកិត្តិគុណនឹងសេចក្ដីសង្ឃឹមនៃព្រះមហាក្សត្រិយ៍ជាព្រះបរមរាជបិតា ហើយជាទីពេញព្រះរាជហឫទ័យនៃព្រះនាងយសោធរា; ព្រះរាជឱរសនោះទ្រង់យាងទៅតំបន់ឆ្ងាយ, ទ្រង់ភ្លេចនឹកនាមករណ៍ព្រះរាជនិវេសនដ្ឋាន ទ្រង់ប្រែព្រះរាជហឫទ័យជាខ្លាំង, ប្រហែលជាទ្រង់ទិវង្គតហើយទេដឹង? ។ តែមានកាលមួយថ្ងៃ ក្នុងវស្សានរដូវ គឺរដូវដែលរុក្ខជាតិស្វាយមានពន្លកត្រួយពណ៌សភ្លឺដូចប្រាក់ ហើយដែលក្រឡាប្រថពីពេញពាសដោយស្លឹកឈើខៀវខ្ចីស្រស់ បុប្ផជាតិមានបុប្ផាគ្រប់ពណ៌ ព្រះនាងទ្រង់គង់ជិតទីដែលមានទឹកហូរ ចែងចាំងក្នុងព្រះរាជឧទ្យានមានដើមបទុមដុះដេរដាស, ទ្រង់ព្រះចិន្ដានឹកស្រមៃទៅឃើញដល់អតីតកាល ដែលព្រះនាងទ្រង់យាងទៅក្រសាលជាមួយនឹងព្រះស្វាមី យល់ព្រះស្វាមីយកព្រះហត្ថាឧបស្នេហ៍ស្និទ្ធព្រះនាង ព្រមទាំងយករឹមព្រះឱស្ឋបុត្តសើចស្រួលជាយ៉ាងក្រៃលែង ។ ដោយព្រះនាងទ្រង់ព្រះកន្សែងជាញឹកញយ ត្របកព្រះនេត្រក៏ទន់ទោរទេរាយជាលំដាប់, ព្រះគណ្ឌៈ (ថ្ពាល់) ដែលមានសម្ផស្សគួរឲ្យចេតនា ទៅជាស្គាំងស្គម, រឹមព្រះឱស្ឋដែលមានទ្រង់ទ្រាយស្រស់បំព្រង ឥឡូវស្ងួតស្រពោនដោយសេចក្ដីទុក្ខលំបាក, ព្រះកេសាមានពន្លឺចាំងចែងតែងមានចុងក្លួចមូលដូចស្រីមេម៉ាយកាន់ទុក្ខ, ព្រះនាងមិនបានទ្រង់នូវគ្រឿងអលង្ការ ហើយគ្មានគ្រឿងមាសអ្វីជាលំអនៃព្រះពស្ត្រកាន់ទុក្ខដែលមាន

សភាពគាគ្រឹម មានពណ៌ស ដែលមានចុងពន្លុំមកខាងព្រះឧរព្រះនាង ។ ព្រះបាទាព្រះនាងមានសភាពតូចល្អសម, ពីដើមធ្លាប់រហ័សរហួនដូចសត្វឈ្លូស (gazelle) ឬស្លឹកផ្កាកុលាបស្រាលហើរលើអាកាសក្នុងពេលដែលព្រះស្វាមីទ្រង់មានព្រះរាជត្រាស់មកម្ដងៗ, ឥឡូវទៅជាកំរើកមិនរួច ។ ព្រះនេត្រព្រះនាងមានរស្មីប្រកបដោយសេចក្ដីស្នេហា, ពីដើមដូចជាព្រះសុរិយាចាំងថែងក្នុងទីងងឹតអន្ធការ, តែឥឡូវមានពណ៌ស្រអាប់ ហើយទតមិនយល់ទិសតំបន់; ព្រះនេត្រនេះពិនិត្យមិនបានឃើញសព្វគ្រប់នូវអច្ឆរិយភាព នៃទិវាយៈរដូវដែលទើបនឹងបដិសន្ធិថ្មីៗ ដោយហេតុថាត្របកព្រះនេត្រដែលមានព្រះលោមាក្លឺប្រាល ធ្លាក់ស្រយង់ក្បិតជិតពីលើរង្វង់ព្រះចក្ខុ ។ នៅព្រះហស្តខ្វាង ព្រះនាងទ្រង់កាន់ព្រះកាយពន្ធន៍ (ceinture) ដែលមានដាំគជខ្យង់របស់ព្រះសិទ្ធត្ថ ដែលព្រះនាងទ្រង់បានរក្សាទុកតាំងពីព្រះពោធិសត្វទ្រង់យាងទៅបព្វជាក្នុងវេលារាត្រីមកម្ល៉េះ ។ ឱយប់នោះជាយប់ប្រកបដោយសេចក្ដីទុក្ខលំបាកដ៏លើសលុប ! តើសេចក្ដីស្នេហារបស់ខ្ញុំ បើប្រៀបធៀបនឹងសេចក្ដីស្នេហារបស់ព្រះអង្គដែលមានចំពោះខ្ញុំ នឹងមានព្រំដែនទៅតាមជីវភាពប៉ុណ្ណាទៅ ? ។ ព្រះហស្តខ្វាងទៀត, ព្រះនាងទ្រង់ដឹកព្រះរាជបុត្រ ១ អង្គ មានលំអជាទិព្វដែលជាព្រះកេរ្តិ៍នៃព្រះសិទ្ធត្ថជាព្រះរាជស្វាមី; ព្រះរាជបុត្រនោះព្រះនាម "រាហុល" មានព្រះជន្មាយុ ៧ ឆ្នាំ

ក្នុងពេលនោះ ។ ព្រះរាជទេវីទ្រង់យាងជិតព្រះវរមាតា ដោយព្រះទ័យសោមនស្សពន់ពេក ព្រោះទ្រង់ទតទៅយល់ក្រាលតាវល្លិ៍មានផ្ការីកស្គុះស្គាយពាសពេញពិភពលោកក្នុងនិទាឃៈរដូវ ។

ព្រះវរមាតានិងព្រះរាជបុត្រ បានយាងទៅប្រថាប់នៅក្បែរស្រះបោក្ខរណីដែលមានដាំបទុម; ព្រះរាហុលទ្រង់មានសោមនស្សជាខ្លាំង ហើយទ្រង់បាចអង្ករទៅឲ្យមច្ឆជាតិមានពណ៌ខៀវផ្ទៃមេឃ និងក្រហមឆ្អៅ; ព្រះនាងទ្រង់ផ្ទៀងព្រះនេត្រ ដោយព្រះទ័យទុក្ខព្រួយបារម្ភជាខ្លាំង មើលទៅបក្សាក្រៀលដែលហើរលឿនលើនភាល័យ ហើយទ្រង់អង្វរ (ថា) ថា: "ឱបក្សាអើយ ! ក្នុងពេលដែលអ្នកធ្វើដំណើរ បើអ្នកបានឃើញនូវទឹកដីដែលព្រះស្វាមីជាទីពេញចិត្តរបស់ខ្ញុំ ស្ថិតលាក់បំពួននៅត្រង់ណា សូមអ្នកទៅឲ្យដំណឹងព្រះអង្គផងថា បើសិនណាជានាងយសោធរាបានឮសូរសៀងព្រះឱស្ឋព្រះរាជស្វាមី ឬទ្រង់បរាមាស (អង្អែល) ដោយព្រះហស្តដ៏ទន់តែមួយស្របក់ នាងសុំមរណាឥតស្តាយជីវិតសោះឡើយ" ។

ក្នុងឱកាសដែលព្រះវរមាតាកំពុងទ្រង់ពិលាប ព្រះរាជបុត្រកំពុងទ្រង់ក្រសាលសប្បាយ, មានពួកស្រីស្នំក្នុងព្រះបរមរាជវាំងបានមកក្រាបបង្គំទូលព្រះនាងថា: "សូមក្រាបបង្គំទូលព្រះនាងទ្រង់ជ្រាប មានពួកពាណិជមកពីស្រុក ហស្តិនបុរ (Hastinpour) ឈ្មោះត្របុស្ស (តបុស្ស)

ទឹងកល្ពក: (កល្ពិក:) ចូលតាមទ្វារ ព្រះបរមរាជវាំងខាងត្បូង ជានាយពាណិជប្រាប់ធ្វើដំណើរតាមមាត់សមុទ្រ ដែលមានរលកបោកជាខ្លាំង បានដឹកនាំសំពត់កោសេយ្យពស្ត្រ, លំពែងមានចុងលាបលនដោយមាស, ថូស្លាទ់ថ្នាក់ក្លុក, គ្រឿងទេស, ស្លឹកឈើឫសថ្នាំផ្សេងៗ, បក្សាដែលកម្រនឹងបានឃើញ នឹងភោគទ្រព្យនៃពួកប្រជាជនស្រុកឆ្ងាយ មកលក់នៅទីនេះ តែពួកពាណិជទាំងនោះបានឃើញច្បាស់ដោយមំសចក្ខុនូវរតនៈអស្ចារ្យវិសេសជាងរតនៈទាំងអស់ក្នុងលោក ។ រតនៈនោះគឺព្រះរាជស្វាមីរបស់ព្រះនាងជាម្ចាស់នៃយើងខ្ញុំទាំងអស់គ្នា, មហាបុរសជាទីសង្ឃឹមនៃប្រទេសជាតិក្នុងអនាគតគឺព្រះសិទ្ធត្ថនោះឯង ។ ពួកទាំងនេះបានឃើញនូវព្រះអង្គហើយ ធ្វើគារវកិច្ចដោយអញ្ជលីព្រមទាំងបានបូជាព្រះអង្គដោយគ្រឿងអាមិសផ្សេងៗ ព្រោះព្រះអង្គដូចជាគេបាននិទានតាមពុទ្ធព្យាករណ៍ពីមុន, ទ្រង់ត្រឡប់ទៅជាព្រះបរមគ្រូជាម្ចាស់ បានខំស្វែងរកឃើញអរិយធម៌ ជាក់ច្បាស់ដោយព្រះអង្គឯង, ជាមហាបុគ្គលដែលពិភពលោកតែងគោរពបូជា, ជាសត្តបុគ្គល មានព្រះប្រាជ្ញាញាណរកទីបំផុតគ្មាន ជាព្រះសម្មាសម្ពុទ្ធដែលបានជួយស្រោចស្រង់មនុស្សឲ្យផុតពីទុក្ខ ហើយបានឧបត្ថម្ភពួកសត្វ ដោយពុទ្ធោវាទនឹងដោយព្រះមេត្តាករុណាទិគុណដ៏ធំទូលាយ ជាអនេកប្បការជាសាធារណៈបីដូចមេឃ ហើយឥឡូវពួកពាណិជនោះបានពណ៌នា អំពីព្រះអង្គដែលខ្លួនបានឃើញទ្រង់គង់នៅទីកន្លែងនោះ ។ (មា៙៣)

# ឃរាវាសធម្មកថា

## ព្រះគ្រូមុនីសោភ័ណ សេខ-ឆាង សាស្ត្រាចារ្យ
## នៅសាលាបាលីជាន់ខ្ពស់ ភ្នំពេញ

ទេសនាផាក់វិទ្យុឃោសនា ពុទ្ធនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើត ខែអស្សុជ
ឆ្នាំកុរ ឆព្វស័ក ព.ស. ២៤៩ (២៩-១-៤៧)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
សូមនមស្សការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយគោរព) ។

វេលានេះ អាត្មាភាពនឹងសំដែងអំពីឃរាវាសធម៌ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញា នៃពុទ្ធសាសនិកជនតទៅ ។

មុននឹងសំដែងញែកជាមេមាតិកានៃធម៌នេះ សូមអធិប្បាយពាក្យថា ឃរាវាសធម៌សិន ។

ឃរាវាសធម៌ ប្រែថា "ច្បាប់សម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ" ។

ការនៅជាប់ទាក់ទងគ្នា ដោយស្វាមី ភរិយា-មាតា-បិតា-បុត្រធីតា របស់បុរសស្ត្រីអ្នកនៅគ្រប់គ្រងផ្ទះ ហៅថាឃរាវាសៗ ដែលនៅរួមគ្នាជាសង្គមមួយៗ រមែងមានការប៉ះទង្គិចប្រេះស្រាំជាធម្មតា ប្រៀបដូចចានមួយរាវនៅកង្ទីជាមួយគ្នា រមែងរណ្តំគ្នា ប៉ុន្តែគង់មានប្រដាប់សម្រាប់ទ្រាប់កុំឲ្យប៉ះទង្គិចគ្នាបាន ។

ឯពានកាលបើមានវត្ថុអ្វីមួយ ជាទ្រនាប់សម្រាប់រុំខ្ចប់អបស្អុបហើយ គេអាចដឹកនាំទៅកាន់ទីជិត-ឆ្ងាយបានដោយស្រួលតាមប្រាថ្នា ឥតមានរណ្តំគ្នាប្លុះប្រេះស្រាំដែបនាឡើយ មានគួរនាយ៉ាងណាមិញ មានគួរនាដូចជាបុគ្គលអ្នកគ្រប់គ្រងផ្ទះ ក៏ត្រូវមានយកាវសធម៌នេះជាទ្រនាប់ គឺជាច្បាប់សម្រាប់ប្រតិបត្តិ មិនឲ្យឃ្លាងគំនិតគ្នា ដើម្បីឲ្យកើតសេចក្តីសុខស្រួលក្នុងសង្គមនីមួយៗ ដូច្នោះដែរ ។

យកាវសធម៌នោះ តាមច្បាប់ព្រះពុទ្ធសាសនាមានច្រើនយ៉ាង ៗ ក្នុងទីនេះ ទីងសំដែងតែយកាវសធម៌ ៤ យ៉ាង ដែលមាននៅក្នុងគម្ពីរព្រះសុត្តន្តបិដក ភាគ ៣០ ត្រង់យក្ខសំយុត្ត ។

យកាវសធម៌ ៤ យ៉ាងនោះ គឺ:

១ – សច្ចៈ ការទៀងត្រង់

២ – ទមៈ ការទូន្មាន

៣ – ខន្តិ ការទប់ចិត្ត

៤ – ចាគៈ ការបរិច្ចាគ ។

សូមអធិប្បាយមួយម្តងៗ ឲ្យសមគួរដល់ភាពជាយកាវសធម៌ ដើម្បីជាសាធារណប្រតិបត្តិតទៅ ។

សច្ចៈ – ការធ្វើកាយ-វាចា-ចិត្តឲ្យទៀងត្រង់ ស្មោះចំពោះដល់គ្នានឹងគ្នា ហៅថាសច្ចៈៗនេះ បានដល់ភាពនៃបុគ្គលជាអ្នកទៀងត្រង់នឹង

សំឡាញ់ មិនទ្រុស្តមិត្រមានចិត្តស្មោះត្រង់នឹងគ្នា, – ទៀងត្រង់ចំពោះកាលវេលា ដែលជាពេលត្រូវចូលត្រូវចេញ, – ទៀងត្រង់ចំពោះកិច្ចការដែលជាមុខក្រសួងខ្លួនត្រូវធ្វើ ។ ដូចជាទាសកម្មករត្រូវទៀងត្រង់នឹងចៅហ្វាយនាយ ៗ ត្រូវទៀងត្រង់នឹងទាសកម្មករ, ស្វាមីនឹងភរិយាត្រូវត្រង់នឹងគ្នាពប់រកគ្នាមិនក្បត់ចិត្តគ្នា, មាតា-បិតានឹងបុត្រ-ធីតា ត្រូវទៀងត្រង់នឹងគ្នា, ប្រជាជនត្រូវទៀងត្រង់គោរពកោតក្រែងចំពោះរាជការរដ្ឋាភិបាល ។ ចំណែករាជការរដ្ឋាភិបាល ត្រូវទៀងត្រង់នឹងប្រជាជនដែលជាពលរដ្ឋ ដោយការគ្រប់គ្រងរក្សាគ្រប់កាលវេលា ដូចជាមាតា-បិតាថែបាច់រក្សាបុត្រ-ធីតាដូច្នោះ ឲ្យមានការទំនុកទុកចិត្តទៅវិញទៅមក, ការទៀងត្រង់ទាំងអស់នេះ ហៅថាសច្ចៈ ។

សច្ចៈនេះ ជាគុណអាចធ្វើបុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ឲ្យជាទីគោរពកោតក្រែងនៃជនដទៃ ដូចសេចក្ដីដែលពោលមកនេះ ហេតុនោះទើបឈ្មោះថា ឃរាវាសធម៌ ដោយប្រការដូច្នេះ ។

៩៤ – ការហ្វឹកហ្វឺនទូន្មានខ្លួនឲ្យប្រាសចាកភ័យអន្តរាយ ឲ្យប្រាសចាកការគ្នាំគ្នងថោកទាប ដើម្បីឲ្យមានបែបបទសណ្ដាប់ធ្នាប់ ចរិយាល្អ ឈ្មោះថាទមៈ ៗ នេះ លោកនែប្រាប់សេចក្ដីផ្សេងៗគ្នា គឺជួនកាលលោកប្រាប់ថាបានដល់ឥន្ទ្រិយសំវរៈ "ការសង្រួមឥន្ទ្រិយ", ជួនកាលថាបានដល់វិបស្សនាបញ្ញា "ប្រាជ្ញាជាគ្រឿងឃើញច្បាស់" ។ តែក្នុងទីនេះ

សំដៅយកការហាត់ពត់កាយ - វាចា - ចិត្ត ឲ្យមានចរិយាល្អ សុតសុភាព រាបសា កុំឲ្យប្រព្រឹត្តទុច្ចរិតផ្សេងៗ កុំឲ្យប្រព្រឹត្តនូវអបាយមុខដែលជាផ្លូវនាំឲ្យវិនាស ខិលខូចប្រទ្បើសបើសដើរលេងល្បែងផ្សេងៗ ដោយប្រែកលួកឥតប្រយោជន៍ ។

មួយទៀតបុគ្គលត្រូវបង្ហឹកខ្លួន ឲ្យបានសមគួរដល់វ័យទាំង ៣ គឺវ័យទី ១ ត្រូវខំប្រឹងសង្វាតរកវៀនវិជ្ជា កុំបណ្តោយឲ្យវ័យទី ១ កន្លងទៅឥតប្រយោជន៍, វ័យទី ២ ត្រូវចុះដៃធ្វើការស្វែងរកទ្រព្យសម្បត្តិឲ្យបានទាន់វ័យនៅមានកម្លាំង កុំខ្ជិលទ្រមក់ដំអក់ទម្រន់, វ័យទី ៣ ត្រូវមីមាស្រាវរកធម៌ មកប្រតិបត្តិបម្រុងប្រាណឲ្យបានជាទីពឹងទៅក្នុងលោកខាងមុខ; ការទូន្មានខ្លួនក្នុងវ័យទាំង ៣ នេះ ហៅថាទមៈ ។

មែនពិត ពួកមនុស្សតាមតែក្នុងប្រទេសណា ដម្បន់ណាក៏ដោយ បើប្រាសចាកធម៌ទមៈនេះហើយ មិនយូរប៉ុន្មានទេ ពួកមនុស្សនៅក្នុងប្រទេសនោះ ដម្បន់នោះ មុខជានឹងរយីករយាកគ្មានសណ្តាប់ធ្នាប់ ជាហេតុឲ្យថោកជាតិ ទាបវាសនាថយចុះសម្រែមទៅតាមលំដាប់ រហូតដល់បានឈ្មោះថា ជាមនុស្សកំពេលឬមនុស្សព្រៃ អំពីសំណាក់លោកអ្នកប្រាជ្ញគ្រប់សម័យ ។

ទមៈនេះ ជាគុណធ្វើមនុស្សថោកទាប ឲ្យបានខ្ពង់ខ្ពស់មានសណ្តាប់ធ្នាប់ចរិយាល្អ អាចក្រៃឡើងជាតិ កែវាសនា ឲ្យក្លាយទៅជាអរិយៈទី ១

កុងអរិយៈទាំង ៤ ពួក គឺៈ អាចារិយៈ (ខ្ពង់ខ្ពស់មារយាទ) ១, ទស្សនារិយៈ (ខ្ពង់ខ្ពស់ដោយការឃើញ) ១, លិង្គារិយៈ (ខ្ពង់ខ្ពស់ភេទ) ១, បដិវេធារិយៈ (ខ្ពង់ខ្ពស់ដោយការត្រាស់ដឹង) ១ ។ អ្នកដែលបានដល់នូវភាពដ៏ថ្លៃថ្លាយ៉ាងនេះ ក៏ដោយមានទមធម៌នៅប្រចាំក្នុងចិត្ត ហេតុនោះទើបឈ្មោះថា យកាំសធម៌ ដោយប្រការដូច្នេះ ។

ឫតិ — ការទប់ចិត្តចំពោះសេចក្ដីទុក្ខ ដែលជាហេតុឲ្យកើតលោភៈ ទោសៈ មោហៈ ហៅថាឫតិ ឬហៅថា ខន្តិ (សេចក្ដីអត់ធន់) ក៏បាន ។

ការអត់ធន់ចំពោះសេចក្ដីទុក្ខ ដែលជាហេតុឲ្យកើតលោភៈនោះ បានដល់ការអត់ធន់ចំពោះចំណង់ផ្សេងៗ ដែលកើតឡើងក្នុងទ្វារទាំង ៦ មានការអត់ធន់មិនប្រព្រឹត្តទុច្ចរិតតាមចំណង់ ឬសេចក្ដីស្រេកឃ្លាននោះៗ ព្រោះបុគ្គលអ្នកមិនចេះអត់ធន់នឹងចំណង់ ឬសេចក្ដីស្រេកឃ្លានហើយ មុខជានឹងលួចឆក់ដណ្ដើមបំបាត់ប្រវ័ញ្ចទ្រព្យសម្បត្តិរបស់គេ, កាលបើប្រព្រឹត្តទុច្ចរិតដូច្នោះ រមែងជួបប្រទះនឹងសេចក្ដីទុក្ខព្រួយ ដែលជាផលរបស់ទុច្ចរិតនោះៗ មានត្រូវទោសជាប់គុកជាប់ច្រវាក់ជាដើម ។ បុគ្គលឯណា ចេះទប់ចិត្តមិនវង្វេងរកមហួសពេក បុគ្គលនោះឯងតែងជួបប្រទះនឹងសេចក្ដីសុខ-ចំរើន ។ ការអត់ធន់យ៉ាងនេះ ហៅថាអត់ធន់ចំពោះលោភៈ ។

ការអត់ធន់ចំពោះទុក្ខ ដែលជាហេតុឲ្យកើតទោសៈនោះ បានខាងការអត់ធន់នឹងពាក្យបញ្ឆិតដែលបុគ្គលដទៃស្ដីថា ត្មះតិះដៀល ឬអត់ធន់

ចំពោះបុគ្គលដទៃបៀតបៀន ដែលជាហេតុឲ្យកើតទោសៈ ដូចនៅក្នុងសង្គមនីមួយៗ គឺស្វាមីនឹងភរិយា ត្រូវមានសេចក្ដីអត់ធន់ទៅវិញទៅមករកគ្នា មាតាបិតានឹងបុត្រធីតា ទាសកម្មករនឹងចៅហ្វាយនាយ, ប្រជាជននឹងរាជការរដ្ឋាភិបាល ក៏ត្រូវមានសេចក្ដីអត់ធន់ មានការគោរពរាប់អានគ្នាជាទីទុកចិត្តគ្នាទៅវិញទៅមក យ៉ាងនេះជាដើម ហៅថាការអត់ធន់ចំពោះទោសៈ ។

ឯសេចក្ដីអត់ធន់ចំពោះសេចក្ដីទុក្ខ ដែលជាហេតុឲ្យកើតមោហៈ នោះបានដល់ការអត់ទ្រាំនឹងទុក្ខវេទនាលំបាកផ្សេងៗ ដែលកើតឡើងក្នុងកាយនឹងចិត្ត មិនឲ្យលុះក្នុងអំណាចទុក្ខវេទនាហើយទៅប្រព្រឹត្តទុច្ចរិតឡើយ ។ សូម្បីការអត់ទ្រាំនឹងទុក្ខវេទនាក្នុងវេលាឈឺថ្កាត់នោះសោត ក៏ជាហេតុជួយឧបត្ថម្ភឲ្យមានសតិសម្បជញ្ញៈ គឺសេចក្ដីរឭកនឹងសេចក្ដីដឹងខ្លួនដែលជាគុណវិសេសគួរឲ្យមានក្នុងចិត្តគ្រប់កាលទាំងពួង ។ ពុំនោះសោតក្នុងវេលាមានព្យាធិ ដែលជាហេតុឲ្យដល់មរណៈ ក៏ត្រូវតែមានការអត់ធន់ខានមិនបាន ព្រោះថា បុគ្គលណាកាលបើបណ្ដោយឲ្យមោហៈគឺសេចក្ដីវង្វេងកើតឡើង នឹងធ្វើការអ្វី ក៏ធ្វើទាំងកំពេលទាំងងងឹត, គិតការអ្វីក៏គិតទាំងបំពាន បុគ្គលនោះរមែងទទួលផលនៃសេចក្ដីទុក្ខដោយពិត ។

បុគ្គលឯណាអត់ទ្រាំចំពោះទុក្ខវេទនា ដែលជាហេតុឲ្យប្រព្រឹត្តទុច្ចរិតផ្សេងៗ, បុគ្គលនោះ រមែងទទួលផលនៃសេចក្ដីសុខចំរើន បើមិនច្រើនក៏តិចពុំខាន ។ ការអត់ធន់បែបនេះ ហៅថាអត់ធន់ចំពោះមោហៈ ។

ការបញ្ឈប់ទប់ចិត្តចំពោះសេចក្ដីទុក្ខ ដែលជាហេតុឲ្យកើតលោភៈ ទោសៈ មោហៈ ដូចពោលមកហៅថាបរិត្ត នេះ ជាគុណធ្វើបុគ្គលអ្នកគ្រប់គ្រងផ្ទះ ឲ្យជាទីស្រឡាញ់ពេញចិត្តនៃជនច្រើនគ្នា, មិនឲ្យមានពៀរវេរាច្រើន មិនឲ្យមានទោសច្រើន មិនឲ្យភាំងភ្លេចស្មារតីក្នុងវេលាជិតស្លាប់, លុះស្លាប់ហើយទៅកាន់លោកខាងមុខ នឹងបានកើតក្នុងសុគតិ-កព ហេតុនោះ ទើបឈ្មោះថា យកកាំសធម៌ ដោយប្រការដូច្នេះ ។

ចាគៈ – ការចំណាយទ្រព្យសម្បត្តិ ទំនុកបម្រុងព្រះពុទ្ធសាសនា កសាងសេនាសនៈ លើកថ្នល់ សង់ស្ពាន ជីកអណ្ដូងទឹក សង់សាលាសម្រាប់បម្រុងការសិក្សារៀនសូត្រ សង់មន្ទីរពេទ្យ សម្រាប់ព្យាបាលអ្នកជម្ងឺជាដើម ហៅថាចាគៈ ។

ពុទ្ធសាសនិកជន ជាអ្នកមានកតញ្ញូកតវេទី គោរពកោតក្រែងព្រះពុទ្ធ-សាសនា តែងតែចំណាយធនធានបូជាព្រះពុទ្ធសាសនា ដូចជាកសាងកុដិ-សាលា-វិហារជាដើម ទើបឈ្មោះថាជាអ្នកគោរពចំពោះសាសនា យ៉ាងណា ប្រជាជនដែលជាពលរដ្ឋ ក្នុងប្រទេសនីមួយៗក៏យ៉ាងនោះដែរ គឺត្រូវតែបរិច្ចាគទ្រព្យបូជាជាពន្ធដារ មានបង់ពន្ធដារសម្រាប់ប្រទេសជាដើមទើបសមស័ក្ដិខ្លួន ជាពលរដ្ឋរបស់ប្រទេស, ទាំងអស់នេះក៏ហៅថា ចាគៈដែរ ។

ចាគៈនេះទុកជាស្នេហ៍មុខធ្វើមនុស្សអ្នកនៅគ្រប់គ្រងផ្ទះ ឲ្យបានជាទីចាប់ចិត្តពប់អានទៃទេវតានឹងមនុស្សទាំងឡាយ ហេតុនោះទើបឈ្មោះថាយកាវាសធម៌ ដោយប្រការដូច្នេះ ។

ធម៌ទាំង៤ប្រការនេះ បើមានបរិបូណ៌ក្នុងបុគ្គលឯណា បុគ្គលនោះតែងបានសេចក្ដីសុខ-ចំរើន រីករាយមិនក្រៀមក្រំចិត្តក្នុងលោកនេះនឹងលោកខាងមុខដោយពិត ។ ព្រោះហេតុនោះបានជាព្រះទសពលទ្រង់សំដែងថា:

យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមាសិនោ
សច្ចំ ធម្មោ ធិតិ ចាគោ ស វេ បេច្ច ន សោចតិ
ឥង្ឃ អញ្ញេបិ បុច្ឆស្សុ បុថុ សមណព្រាហ្មណេ
យទិ សច្ចា ទមា ចាគា ខន្ត្យា ភិយ្យោធ វិជ្ជតិ ។

" បុគ្គលដែលមានសទ្ធាគ្រប់គ្រងផ្ទះ ត្រូវមានធម៌ ៤ ប្រការនេះគឺៈ សច្ចៈ (ការទៀងត្រង់) ១, ទមៈ (ការទូន្មាន) ១, ធិតិ (ការទប់ចិត្ត) ១, ចាគៈ (ការបរិច្ចាគ) ១, រមែងមិនសៅសោកក្នុងលោកខាងមុខដោយពិត, បើដូច្នោះ អ្នកចូរសួរសមណព្រាហ្មណ៍ឯទៀតឲ្យច្រើនគ្នាចុះ ក្រែងមានធម៌ណាក្នុងលោកនេះវិសេសជាង សច្ចៈ ទមៈ ចាគៈ ខន្តិ ទៅទៀត " ។

ធម៌មានសច្ចៈជាដើមនោះ ឈ្មោះថាឃរាវាសធម៌គឺច្បាប់សម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ប្រតិបត្តិដើម្បីកុំឲ្យមានការប៉ះទង្គិចប្រេះឆាជ, ច្បាប់សម្រាប់តម្រង់នូវសង្គមនីមួយៗ ឲ្យមានសាមគ្គី សេចក្ដីព្រមព្រៀងគ្នា ឲ្យមានសេចក្ដីគោរពរាប់អានគ្នា មានទំនុកទុកចិត្តគ្នាជាបំផុត ។

ពណ៌នាធម្មកថាអំពីឃរាវាសធម៌ ៤ យ៉ាង ក៏សូមសន្មតបញ្ចប់ត្រឹមប៉ុណ្ណេះ, សូមជូនពរចំពោះអស់លោក-អ្នកទាំងឡាយ ឲ្យបានប្រកបដោយឥដ្ឋមនុញ្ញផលគ្រប់ៗគ្នា ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ

សព្វសត្វទាំងឡាយ ដែលដល់នូវសេចក្ដីទុក្ខ សូមឲ្យជាអ្នកឥតទុក្ខទៅ! ដែលដល់នូវភ័យ សូមឲ្យជាអ្នកឥតភ័យទៅ! ដែលដល់នូវសោក សូមឲ្យជាអ្នកបាត់សោកទៅ! ។

រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ
វុឌ្ឍឹ វិរុឡ្ហឹ បប្បោន្តុ សន្តិភាវញ្ច ជាញ្ញតា.

ដោយតេជះនៃព្រះរតនត្រ័យ (ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ) សូមឲ្យប្រជាជនទាំងឡាយ អ្នកនៅកម្ពុជរដ្ឋ ដល់នូវការលូតលាស់ចំរើន នឹងសន្តិភាព កុំបីឃ្លាតក្លាយទៅជាបការដទៃឡើយ! ។

---

## ការបណ្តុះនិស្ស័យ

## ព្រះមហាឧត្តមវិជ្ជា ធិលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណានុរក្ស ប៊ូ ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

១) កិរិយារម្យទម — នៅត្រង់ការស្ងប់ស្ងៀម, ការរៀបរយ, ការសុភាពរាបសា, ការស្គាល់ប្រមាណខ្លួន, ការឧបអរសាទរ, មេត្តាករុណានឹងការអើពើទទួលអញ្ជើញរាក់ទាក់ ។ ការតាំងនៅក្នុងក្រប-ខ័ណ្ឌនៃសីលធម៌ដូចពោលមកនេះ ចាត់ជា "កិរិយារម្យទម" ព្រោះជារបស់ល្អ នឹង គួរមើលនៃជនទូទៅ ។ ដ្បិតអាការរម្យទមនោះ ជាកិរិយាមិនរឹងត្អឹង, មិនប្រងើងប្រឆាំង, មិនអាក្រក់ឃោឃៅ នឹងមិនឈ្លើយប្រឡើសប្រើស ។

មនុស្សនិស្ស័យរឹងត្អឹង តែងសំដែងកិរិយាឃោឃៅប្រងើងប្រឆាំងមើលងាយមនុស្សដទៃ ដូចយ៉ាងឈរបង្អាប់ ឈរឲ្យឬហុចរបស់អ្វីឲ្យគេ ដោយអាការក្រអឺតក្រទម ព្រមទាំងនិយាយពាក្យមិនគួរស្តាប់ជាដើម ឬក៏ដើរចៀសពីគេទៅ ដោយអាការប៉ះទង្គិច តក់តក់កោស; ដើរជិតឬឈរជិតអ្នកដែលអង្គុយ ដោយទំនងដូចជាកន្ទង់សីសៈ ឬដូចជាឈរប្រត់សីសៈគេ, ចួនកាលក៏ឥតពិចារណា រំកែគេចេញទៅ ដោយឥត

សូមទោសឬប្រាប់គេជាមុន, កាលអង្គុយឬឈរទទឹងផ្លូវឃើញគេទៅមក ដែលខ្លួនគួរចៀស ក៏ធ្វើព្រងើយមិនចៀស, បើមានក្មេងទៅមក ដែលខ្លួនគួរសំដែងកិរិយាហៅរកកក់ទាក់ប្រស្រ័យ ដោយអធ្យាស្រ័យដ៏ល្អ ក៏ត្រឡប់ជាឈរមើលដោយភ្នែកអាក្រក់ទៅវិញ, សូម្បីបានឮគេនិយាយអ្វី ក៏បដិសេធរបស់គេបោលគ្រប់យ៉ាង ។

មនុស្សនិស្ស័យប្រឆេងប្រឆាំង តែងសំដែងកិរិយារឹងរូសមើលងាយ លើកខ្លួនសង្កត់អ្នកដទៃទាំងអស់ ទឹងធ្វើអ្វីក៏មិនផុតអំពីការវាយដំឡើងខ្លួនឲ្យលើសមនុស្សដទៃឡើយ ។ សូម្បីទឹងធ្វើសេចក្ដីល្អ ក៏មិនសូវមាននរណាគេស្រឡាញ់គាប់ចិត្តដែរ ហើយចូលចិត្តប្រកាន់ខ្លួនលើកដំកើងខ្លួនជានិច្ច ព្រោះសំគាល់ខុសថា "ការទន់លំទោនជាការមើលងាយខ្លួនឯង ជាការមិនរាប់អានខ្លួនឯង" ។ តាមពិត ការប្រព្រឹត្តទន់លំទោននោះ គឺការមិនប្រកាន់ខ្លួនឲ្យហួសប្រមាណ ទឹង មិនបន្ទាបខ្លួនគួរសមហួសពេក ។ ការប្រព្រឹត្តល្អបែបនេះ ជាឧបាយបិទផ្លូវមិនឲ្យអ្នកដទៃមើលងាយខ្លួនបាន មិនមែនជាការមិនរាប់អានខ្លួនឯងឡើយ ។ តែព្រោះនិស្ស័យប្រឆេងប្រឆាំង នាំឲ្យចូលចិត្តខុស ទើបរាប់អានខ្លួនឯងហួសហេតុ ទាល់តែធ្វើខ្លួនឲ្យមានកិរិយាប្រឆេងប្រឆាំង ក្លាយទៅជាសត្រូវចំពោះខ្លួនឯងវិញ ។

អ្នករឹងរូស រឹងត្អឹង ប្រដៅក្រ
មិនគោរព និករ ជនខ្ពស់ទាប

ដើរប្រៀបប្រៀត គេឯង មិនមើលភាព
គង់បានប្រាប ពាក្យជេរ ពីគេវិញ ។

អ្នកមាននិស្ស័យរឹងត្អឹងទឹងប្រងើងប្រងាង មានកិរិយាអាក្រក់ថោកទាប រមែងធ្វើឲ្យមនុស្សដទៃស្អប់ខ្ពើមទឹកមុខ មិនចង់រាយស្និទ្ធជិតជិតទាំងជាការប្រានបណ្ដេញខ្លួនឯងឲ្យចេញចាកសមាគមផង ។ ឯអ្នកដែលមានកិរិយាល្អវិញ កិរិយានោះនឹងជាគ្រឿងប្រជាប់ដឹកនាំ ឲ្យមានមនុស្សដទៃនិយមរាប់អានស្រឡាញ់ប្រាថ្នាសេពគប់ ។ តាមពិត កិរិយាអាក្រក់រមែងជាសត្រូវចំពោះខ្លួនឯង ។ សេចក្ដីល្អពិតៗក៏ដោយ បើយើងធ្វើដោយអាការអាក្រក់ហើយ សេចក្ដីល្អនោះ ក៏ត្រូវវិនាសបាត់បង់ទៅដែរ ។ កិរិយាល្អឈ្មោះថាជាមិត្តរបស់ខ្លួនឯង អាចជួយជាកំឡាំងក្នុងការតស៊ូចំពោះឧបស័គ្គផ្សេងៗ, ធ្វើសេចក្ដីចូលចិត្ត ព្រមព្រៀងគ្នា ឲ្យដំណើរទៅដោយរៀបរយ ប្រៀបដូចដៃដែលសម្រាប់ជួយរៀបចំការងារខាងមុខឲ្យរៀបរយដូច្នោះ ។

ការសំដែងកិរិយាមារយាទចំពោះគ្នានឹងគ្នា ជាការសំខាន់បំផុតគួរប្រយ័ត្នថែរក្សាឲ្យមែនទែន ដូចយ៉ាងមិត្តភក្តិក្នុងភូមិ គេមានកិច្ចរវល់យ៉ាងណាមួយ ហើយគេមកសូមជំនួយអំពីយើង ។ បើយើងឲ្យគេដោយអាការអាក្រក់ ដោយអាការទើសទាល់ឬដោយអាការមុខក្រញូវហើយ ក៏ជាហេតុនាំឲ្យគេធុញទ្រាន់ដល់ទៅអធ្យាស្រ័យរបស់យើងថា

យើងមិនពេញចិត្តនឹងឲ្យគេ ។ នេះឈ្មោះថាធ្វើគុណដោយសេចក្ដីទើសទាល់ ។ គុណដែលយើងនឹងគប្បីបានទទួលមកវិញនោះ សូម្បីប្រផងនឹងបានច្រើនក៏រួញចុះមកនៅត្រឹមតែតិចតួច ។ បើយើងឲ្យដោយអាការល្អវិញ ក៏អាចសំដែងឲ្យគេឃើញប្រាកដថា " យើងឲ្យដោយទឹកចិត្តដ៏ប្រកបដោយមេត្តាករុណា ប្រាថ្នានឹងសង្គ្រោះក្នុងកាលគេមានទុក្ខធុរៈ នឹង មានឧបស័គ្គពិតៗ ឥតបង់បានប្រយោជន៍ណាមួយអំពីគេមែន " ។ នេះឯងឈ្មោះថាធ្វើគុណដោយមិត្តភាព ។ ការធ្វើឧបការបែបនេះ សូម្បីតែបន្តិចបន្តួច ក៏អាចនឹងបន្ទន់ចិត្តអ្នកទទួល ឲ្យកើតសេចក្ដីស្រឡាញ់កក្ដី នឹង មានកតញ្ញូចំពោះយើងបាន ។

កិរិយាល្អ ជាគ្រឿងចងចិត្តមិត្តភក្ដិ នឹង ការប្រមូលអ្នកដទៃក្នុងលោកឲ្យចូលមកសេពគប់នឹងយើង ធ្វើឲ្យយើងមានមិត្តភក្ដិពួកម៉ាកច្រើនគ្នា ។ ចំណែកកិរិយាអាក្រក់វិញជាគ្រឿងបណ្ដុះសត្រូវ បណ្ដេញខ្លួនឯងឲ្យចេញទៅឆ្ងាយអំពីមនុស្សដទៃៗ ក្នុងលោក ធ្វើខ្លួនឲ្យបានទទួលសេចក្ដីទុក្ខក្ដៅក្រហាយតែម្នាក់ឯង ។ ដូច្នេះ យើងគួរអប់រំកិរិយាល្អទុក ដោយកុំមានទិដ្ឋិមានះប្រកាន់ខ្លួន មើលងាយគេ កុំប្រើកិរិយារឹងរូសនឹងកិរិយាច្រនែងច្រងាង គួរស្គាល់ប្រមាណខ្លួន ដូចគោបាក់ស្នែងឬអាសិរពិសដែលគេដកចង្កូមចេញ ។ បើយើងមានកិរិយាជាមនុស្សល្អហើយ ក៏នឹងទៅជាទីជួយលើកទឹកចិត្តនៃគ្នានឹងគ្នា ជាទីស្រឡាញ់ចូលចិត្តនៃគ្នានឹង

គ្នា នឹងជាទីបង់បិត្តនៃគ្នានឹងគ្នា ឲ្យមានការជិតដិតស្និទ្ធស្នាលនឹងស្គាល់គ្នាឯងបាន ដូចជាញាតិដែលជិតដិតដូច្នោះ ។ បើយើងមានកិរិយាល្អ, ស្ងប់ស្ងៀមរៀបរយពេញទីហើយ ឥតមានអ្វីអាចធ្វើឲ្យយើងប្រែប្រួលអំពីសេចក្តីស្ងប់ស្ងៀមរៀបរយបានឡើយ ។

មានកេរ្តិ៍ឈ្មោះ ខ្ពស់ខ្ពង់ វង្សស្រុកស្តួក
កុំប្រទុំ កន្តជ្រួស ហួសយសសក្តិ
គួរឲ្យស្គាល់ ប្រមាណ ហានជាន់ថ្នាក់
ទើបកេរ្តិ៍ឈ្មោះ ដៀងជាក់ ល្បីសុសសាយ ។
បើលំទោន ទុនត្លួ គួរសមផង
កេរ្តិ៍ឈ្មោះរឹត គឹកកង ល្បីទៅឆ្ងាយ
គ្រាមនិគម ជនបទ ផងទាំងឡាយ
សឹងប្រញាយ ចុះបួល មូលមេត្រី ។
បើសក្តិខ្ពស់ ជ្រួសបុក ក្អកក្អេបអង្គ
ទ្រើសទ្រនង់ យង់យួង ជងអប្រិយ
កិត្តិយស ខ្ពស់ខ្ពង់ គង់ដេកដី
អ្នកក្រក្រី មិនខ្ចី ទាំងខ្លាចផង ។

គ) កិរិយាឱនលំទោន — នៅត្រង់ការសំដែងអាការចេញមកជាកិរិយាសម្មាគារវៈទុនលំទោន គោរពប្រណិប័តន៍ចំពោះអ្នកស្រុកស្តួក

អ្នកជំទឹងអ្នកស្មើគ្នា ព្រមទាំងអ្នកតូច ឬអ្នកមានឋានៈទាបជាង, មិន លំបាកប្រដៅ មិនអួតអាងមិនរឹងរូស មិនមើលងាយគេ មិនប្រកាន់ ដោយទិដ្ឋិមានះ ។

មនុស្សប្រដៅក្រ មើលងាយគេ ចូលចិត្តសំដែងកិរិយាលើកដំកើង ខ្លួនឯងហើយបន្ទាបគេ ជាមនុស្សរឹងត្អឹង អាក្រក់ជួជាតិ មុខរឹង ទាំង រីកក្រយក្នុងចិត្តតែខាងការមើលងាយគេ និងការឈ្លើសឈ្លង មិនបង្អោន ខ្លួនគោរពជឿស្តាប់នរណា សំគាល់ខ្លួនថាជាមនុស្សល្អ មនុស្សខ្ពស់ជាង គេទាំងអស់, បើឃើញនរណាមួយហើយ ច្រើនតែតាំងលំនាំពាក្យបុក ក្រអឺតក្រទម, ដើម្បីឲ្យគេគោរពខ្លួនមុនជានិច្ច សូម្បីធ្លាប់ស្គាល់និងធ្លាប់ គោរពគ្នាក្នុងទីកន្លែងដទៃខ្លះមកហើយក៏ដោយ តែកាលបានចួបគ្នា ក្នុង ទីដទៃទៀត ក៏ប្រែជាពាក្យប្រកាន់ខ្លួន ធ្វើជាពើមិនស្គាល់ លែង គោរពគ្នាទៅវិញទៅមកទៀត ឬបើទុកជាធ្វើសេចក្តីគោរពក៏គ្រាន់តែធ្វើ ទៅដោយសារអំណាចឬបុណ្យវាសនាឬក៏ព្រោះរបៀប ពុំនោះព្រោះ ច្បាប់បង្គាប់ឲ្យធ្វើប៉ុណ្ណោះ មិនបានធ្វើដោយសុទ្ធចិត្តឡើយ ។

មនុស្សមើលងាយគេ មានលក្ខណៈដំឡើងបុក ពាក្យបុកជានិច្ច មានចិត្តក្អឹតក្អើនហេហា សំគាល់ថាមិនមាននរណាប្រសើរជាងខ្លួន ទាំងចូលចិត្តមើលងាយ លុបគុណអ្នកដទៃ សំគាល់ឃើញថាគេថោក ទាបជាងខ្លួនទាំងអស់ មិនចេះថែរក្សាកិរិយាអធ្យាស្រ័យ ចំពោះអ្នកដទៃ

តាមដែលគួរឡើយ តាំងមិនស្គាល់ប្រមាណខ្លួន លើកកំពស់ខ្លួនហួសប្រមាណ រាយប្ញុកក្រអឺតតាមតែគំនិតដែលខ្លួនយល់ឃើញថាល្អថាគួរ ។ តែអ្នកដទៃ គេឃើញថា ជាប្ញុកអាក្រក់គួរខ្ពើម គួរធុញ គួរស្អប់ទៅវិញ ប្រៀបដូចសត្វអម្ពិលអម្ពែក ចង់រាយប្ញុកឲ្យស្មើនឹងព្រះចន្ទ ។ កិរិយាប្រឡើសបើសតាំងនេះ ជាច្រកនៃសេចក្ដីវិនាស ដូចពុទ្ធភាសិតក្នុងបរាភវសូត្រថា :

ជនឯណា កបកើត កំណើតខ្ពស់
មានទ្រព្យច្រើន កើតយស ត្រកូលស្តុក
តែមើលងាយ ញាតិខ្លួន ដែលមានទុក្ខ
នេះជាហេតុ បរាមុខ នៃជននោះ ។

កិរិយាទន់លំទោន ជាច្រកនៃសេចក្ដីចំរើន ជាគ្រឿងសំគាល់របស់មនុស្សល្អ, កាលបើមាននៅក្នុងសន្ដានរបស់អ្នកណាហើយ ក៏អាចបង្ហាញឲ្យគេឃើញបានថា អ្នកនោះជាមនុស្សល្អ, បើមិនមាននៅក្នុងខ្លួនអ្នកណាហើយ ក៏ធ្វើអ្នកនោះឲ្យអាប់រាសី ប្រៀបដូចផ្ទះអ្នកណាដែលមិនមានកន្លែងសម្រាប់ធ្វើសក្ការបូជា ក៏អាចបង្ហាញឲ្យគេដឹងថា អ្នកនោះមិនមែនជាពុទ្ធសាសនិកជន ។ បំណែកការប្រមាថមើលងាយគេ ជាគន្លងផ្លូវនៃហាយនៈ ។ បើយើងមិនចង់បានសេចក្ដីវិនាសទេ ក៏ប្ញូរសំដែងតែកិរិយាទន់លំទោនចំពោះមនុស្សខ្លួនទៅចុះ កុំសំដែងកិរិយាដំកើងខ្លួន រឹងរូស ប្រឆេងប្រឆាំង ប្រមាថមើលងាយគេឡើយ ។

កិរិយាល្អ កិរិយារម្យទមនឹងកិរិយាទន់ភ្លន់ទោននេះឯង ហៅថា កិរិយាសុភាព ។ ការសំដែងអាការចំពោះមនុស្សដទៃ ដោយកិរិយាសុភាពនេះ បើយើងប្រតិបត្តិតាមដោយត្រឹមត្រូវជានិច្ច ទាំងក្នុងទីចំពោះមុខទាំងក្នុងទីកំបាំងមុខ ទាំងបេះដូងបេះស្តាប់គ្នាទៅវិញទៅមកបានហើយ ក៏អាចបរិហារការពារពួកគណៈរបស់ខ្លួនឲ្យផុតភ័យវិបត្តិ នឹងឲ្យវឌ្ឍនាការជាស្ថាពរតទៅទៀតបាន ហៅថាជាប្រយោជន៍ចំពោះពួកមនុស្សច្រើន នឹងជាទីស្រឡាញ់នៃគ្នានឹងគ្នាទូទៅ មិនទិយមថ្នាក់និយមជាន់ឡើយ ។ អ្នកតូច រមែងជាទីស្រឡាញ់នៃមនុស្សអ្នកធំ ហើយនឹងបានទទួលការឧបត្ថម្ភគាំពារអំពីអ្នកធំ ។ មនុស្សស្មើគ្នានឹងបានជាទីអាស្រ័យពឹងពាក់នូវគ្នានឹងគ្នា ។ អ្នកធំ ក៏នឹងបានអ្នកតូចជួយជាកំឡាំងសម្បីកាលមានកិច្ចកើតឡើង អ្នកតូចក៏នឹងតាំងចិត្តធ្វើឲ្យសម្រេច ដោយសេចក្តីពេញចិត្ត, នេះសំដែងឲ្យឃើញថា "ការសុភាព មិនមែនជាប្រយោជន៍ចំពោះតែខ្លួន ១ ចំណែកឡើយ គឺរមែងជាប្រយោជន៍យ៉ាងធំចំពោះពួកគណៈរហូតដល់ប្រទេសជាតិទៀតផង" ។

ដូច្នេះ លោក-អ្នកទាំងឡាយ គួរសំដែងកិរិយាសុភាពចំពោះមនុស្សទាំងពួងដោយស្មើមុខគ្នា មិនត្រូវរើសមុខថាគេមានឋានៈខ្ពស់ជាង, ស្មើគ្នា, ទាបជាង ឬថោកទាបជាងយ៉ាងណាឡើយ ។ បើធ្វើបានដូច្នេះហើយ នឹងបានឈ្មោះថាជាអ្នកប៉ិនប្រសប់ខាងការថែរក្សាខ្លួនឲ្យ

សមគួរដល់បរិស័ទ អាចផ្សារបុគ្គលនឹងបុគ្គល, ពួកមនុស្សនឹងពួកមនុស្ស, រហូតដល់ប្រទេសជាតិ ឲ្យជាប់តគ្នាបាន ។ តែកុំប្រើកិរិយាថោកទាប, កិរិយាអាក្រក់ នឹងកិរិយាប្រឆេងប្រឆាំង, លើកដំកើងប្រដៅក្រ, រឹងត្អឹង ប្អាយបុកក្រអឺតក្រអោង ចំពោះនរណា ៗ ឡើយ ។ ព្រោះកិរិយាបែប នេះ មិនមាននរណាចូលចិត្តទេ ។ មនុស្សជាច្រើន តែងពោលរិះគន់ មនុស្ស ដែលមានកិរិយាបែបនេះ ។

ទុនលំទោន ទើបមាន គេចូលចិត្ត
អួតសក្តិយស ហួសក្រិត នាំសៅហ្មង
ព្រោះការទុន ជាពង្ស នៃមាសផង
តែបុកខ្ពស់ កន្ទង នាំលិចលង់ ។

(មានត)

## អ៊ីឡេណា - ស៊ិម្យ៉ាណា

"រឿងព្រេងប្រទេសរូម៉ានី"

# លោក ផេង - ជឺវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

---

នាងអ៊ីឡេណា ស៊ិម្យ៉ាណា លុះបានស្តាប់សំដីនៃនាងបរិចារិការួច ហើយ ក៏ដើរសំដៅទៅរកឈ្មួញដែលឈប់ចាំនៅត្រង់កំពែងដើម្បីមើលស្បែកជើង ៗ ប៉ុន្តែឈ្មួញនិយាយប្រាប់ថា: ទំនិញនៅឯសំពៅមានល្អជាងនេះទៅទៀត ៗ នាងឮដូច្នោះក៏តាមទៅមើលឯសំពៅ ៗ កាល័យតែរើសទំនិញ នាងមិនដឹងថាសំពៅថយចេញពីច្រាំង, ហើយដោយសារព្រះជាម្ចាស់បញ្ជូនខ្យល់មកផង សំពៅបើកចេញមានសន្ទុះយ៉ាងលឿនដូចជាព្រួញ ៗ នាងអ៊ីឡេណា -ស៊ិម្យ៉ាណា ដឹងថាដល់កណ្តាលសមុទ្រហើយក៏ធ្វើជាថែចព្រួយ ហើយបន្ទោសឈ្មួញអំពីការបញ្ឆោតនេះ ៗ តែក្នុងចិត្តនាងមានសេចក្តីត្រេកអរជាអនេក ដោយការបានរួចផុតពីដៃយក្សចង្រៃនេះ ៗ

សំពៅបានដល់ត្រើយយ៉ាងស្រួល ៗ ប៉ុន្តែម្តាយយក្សដឹងដំណឹងតាមស្រីអ្នកបំរើប្រាប់ថា "នាងអ៊ីឡេណា- ស៊ិម្យ៉ាណា មានឈ្មួញមកលួចពង្រត់តាមសមុទ្រយកទៅបាត់ហើយ" ក៏ដេញតាមឥតបង្អង់ឡើយ ៗ

គ្រាន់តែឡើងពីសំពៅសឹងតែមិនទាន់ ព្រះរាជធីតាទ្រង់ជ្រាបភ្លាមថា ដូចជាមានអ្វីដេញតាមខាងក្រោយ រូបរាងដូចជាសីហ៍ ហាមាត់យ៉ាងធំ ពីដីដល់មេឃ ព្រួសសុទ្ធតែអណ្ដាតភ្លើង ។

នាងអឺឡេណា - សិម្យ៉ាណា ដឹងមួយរំពេចថា ប្រាកដជាមេឃគ្គិនីដេញតាមមែន ។ នាងនិយាយរៀងសព្វគ្រប់ប្រាប់ឈ្មួញដែលដាក់ឲ្យអង្គុយលើខ្នងសេះពីក្រោយខ្នង រួចនាងយំខ្សឹកខ្សួលទឹកភ្នែកហូររហាម ។

ព្រះរាជធីតាសួរស្រៀបការអំពីកិច្ចដែលត្រូវធ្វើយ៉ាងដូចម្ដេច ដើម្បីដោះខ្លួនឲ្យរួចពីអណ្ដាតភ្លើងដែលព្រួសមកលើ ។ សេះក្រាបបង្គំទូលថា: សូមទ្រង់ខ្វេះយកត្បូងពេជ្រមួយដុំដែលនៅក្នុងត្រចៀកឆ្វេង របស់ទូលព្រះបង្គំ ហើយទ្រង់ចោលទៅក្រោយទៅ ។ ព្រះនាងក៏ធ្វើតាមបង្គាប់សេះ ហើយនាំគ្នាធ្វើដំណើរតទៅ ។ ចំណែកខាងក្រោយនាងស្រាប់តែដុះភ្នំថ្មតាំងពីដីដល់មេឃ សម្រាប់រាំងផ្លូវយក្ស ។

មេឃគ្គិនីរំព្រាហ៊ានឡើងភ្នំពីថ្មមួយទៅដុំថ្មមួយ មិនយូរប៉ុន្មានក៏បានធ្លងផុតភ្នំហើយចាប់ដេញតាមនាងកិតៗទៅទៀត ។ នាងអឺឡេណា - សិម្យ៉ាណា ឃើញដូច្នោះក៏ឲ្យដំណឹងដល់ឈ្មួញ ។ ធ្វើតាមបណ្ដាំសេះ លូកយកត្រាសមួយពីរន្ធត្រចៀកសេះ ហើយបោះចោលទៅក្រោយទៀត ។ ស្រាប់តែមានព្រៃលេចឡើងយ៉ាងជិតស្និទ្ធ ព្រៃនុះសូម្បីតែសត្វអ្វីមួយក៏រកចូលមិនរួច ។

មេឃក្ខិនីកំទេចដើមឈើទាំងឡាយ គោងពីមែកមួយទៅមែកមួយ លោតផ្លោះពីចុងមួយទៅចុងមួយ រួចបានច្លងផុតទៀត ហើយតាំងបោះដេញតាមងងឹតមេឃ ដូចជាខ្យល់ព្យុះ ។ ព្រះរាជធីតាបានទតព្រះនេត្រឃើញដូច្នោះ សួរសេះម្ដងទៀតថា: តើត្រូវធ្វើដូចម្ដេច? ។ សេះប្រាប់ថា: ត្រូវដោះចិញ្ចៀនពីដៃនាងអីឡេណាសិម្យ៉ាណា បោលទៅក្រោយម្ដងទៀត ។ ចិញ្ចៀនធ្លាក់សឹងមិនដល់ដី ស្រាប់តែដុះកំពែងថ្មបាយក្រៀមឡើង ចាប់តាំងពីប្រថពីទៅទល់មេឃ សម្រាប់កាំងផ្លូវមិនឲ្យយក្សទៅតាមបាន ។

មេឃក្ខិនីដឹងច្បាស់ថា: អាត្មាមុខជាច្លងកំពែងនេះមិនផុតបំពារក៏មិនបែកហើយគិតតែស៊ូដេកនៀលស្លាប់នៅទីនោះ ។ ទាំងក្រោធទាំងទុក្ខព្រួយ ក៏ខំបំពើតកដល់ត្រឹមប្រហោងចិញ្ចៀនដែលក្លាយជាកំពែងហើយខំប្រឹងព្រួសអណ្ដាតភ្លើងតាមចន្លោះនោះ ដើម្បីដុតកំទេចពួករមត់ទាំងប៉ុន្មាន ប៉ុន្តែពួកនេះថយមកនៅអង្គុយក្បែរកំពែង មិនធ្វើជាដឹងអំពីភ្លើងរបស់យក្សឡើយ ។

មេឃក្ខិនីខំផ្លុំព្រួសអណ្ដាតភ្លើង ដោយកំហឹងកាន់តែខ្លាំងឡើងៗ ទាល់តែបែកទ្រូងស្លាប់នៅនឹងកន្លែង ។ ព្រះរាជធីតាទ្រង់ជ្រាបច្បាស់ថា យក្ខិនីក្ស័យជន្មពិតប្រាកដហើយ, ទ្រង់យកម្រាមព្រះហស្តទៅស៊កត្រង់រន្ធចិញ្ចៀនតាមសំដីសេះ, កំពែងក៏វិនាសអន្តរាយបាត់, ចិញ្ចៀន

ផាប់មកនៅកន្លែងអង្គលើវិញ ។ ទុកខ្មោចយក្ខិនីពោល ឲ្យសត្វក្អែកត្មាត ស៊ី ព្រះនាងធ្វើដំណើរមកទៀត រហូតបានដល់នគរព្រះចៅរាជាធិរាជ ។

ជនទាំងអស់គ្នាឡើងទៅក្រាបបង្គំគាល់ព្រះចៅៗ ទ្រង់ទទួលជាឧឡារិក ហើយទ្រង់មានព្រះរាជហឫទ័យសប្បាយជាអស្ចារ្យ ព្រមទាំងប្រកបដោយសេចក្ដីស្នេហាចំពោះនាងអីឡេណា-សម៉្យាណា មួយរំពេចនិមិត្តតែទ្រង់ទតឃើញភ្លាម ។ ប៉ុន្តែសាមីខ្លួននាងអីឡេណា-សម៉្យាណា មិនសប្បាយចិត្តសោះ មានតែសេចក្ដីទុក្ខព្រួយ ព្រោះនាងនឹកគួបចិត្តនឹងព្រេងវាសនាអាក្រក់របស់នាង ប្ដីណាក៏ដូចប្ដីណា មិនដែលមានរូបឆោមល្អពេញចិត្តឡើយ ។ ចិត្តរបស់នាងផ្ដោះទៅរកតែព្រះអង្គម្ចាស់ហារហាន ដែលបានដោះនាងឲ្យបានរួចផុតពីកណ្ដាប់ដៃយក្ស ហើយនាងចេះតែសំឡឹងទៅរកព្រះអង្គម្ចាស់ទុះស៊ីងមិនដាក់ភ្នែក ។

លុះព្រះចៅរាជាធិរាជកំហែងបង្ខំនាងឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងព្រះអង្គ នាងឆ្លើយថា "បពិត្រព្រះមហាក្សត្រិយ៍ដ៏មានរិទ្ធិលើកពផែនដី ! សូមទ្រង់សោយរាជ្យជាសុខក្នុងព្រះរាជរដ្ឋ ។ ចំណែកទូលព្រះបង្គំមិនអាចរៀបអាពាហ៍ពិពាហ៍នឹងព្រះអង្គទេ វេលាណាដែលគេមិនទាន់ប្រមូលមេសេះ នឹងសេះឈ្មោលរបស់ទូលព្រះបង្គំយកមកឲ្យនៅជួបជុំគ្នា" ។

ព្រះចៅត្រាស់ឲ្យហៅព្រះអង្គម្ចាស់ហារហានទៀត ហើយទ្រង់មានព្រះរាជឧង្ការបង្គាប់ថាៈ "ចូរឯងទៅរកប្រមូលសេះទាំងឡាយរបស់ចយ-

នារីរបស់យើងមក គឺថាត្រូវរកឲ្យបានគ្រប់គ្រាន់ទាំងញីទាំងឈ្មោល មកជាកុំខាន" ។

ព្រះរាជធីតាក្រាបបង្គំទូលតបវិញថា: "បពិត្រព្រះបិតាដ៏ទ្រង់នូវអានុភាពខ្ពង់ខ្ពស់! ទូលព្រះបង្គំ ទើបតែបំពេញកិច្ចមួយដែលជាភារៈរបស់ទ្រង់ផ្ដុកឲ្យមក ប្រកបដោយសេចក្ដីលំបាកយ៉ាងធំបំផុត, ដោយយកជីវិតប្ដូរ ។ ចុះនៅក្នុងព្រះបរមរាជវាំងនេះ ខ្វះអ្វីព្រះរាជបុត្រពារពាននៃព្រះរាជាដទៃទាំងឡាយ ។ អ្នកផងទាំងពួងតែងនិយាយថាព្រះករុណាថ្លៃវិសេសប្រកបដោយទសពិធរាជធម៌ គោរពព្រះជាម្ចាស បើដូច្នេះ សូមទ្រង់ព្រះមេត្តាផ្ទេរភារៈថ្មីនេះទៅលើព្រះរាជបុត្រណាមួយផង តើបានឬទេ? តើទូលព្រះបង្គំនឹងអាចទៅរកមេសេះទាំងនោះដូចម្ដេចបាន? ហើយតើមេសេះនោះនៅទីស្ថានណា ប្រមូលមកយ៉ាងដូចម្ដេចទៅ?" ។

ព្រះបិតាទ្រង់ឆ្លើយឡើងថា: "យើងមិនដឹងទេ! ឯងបេះកកាយយកពីក្នុងដីក៏ដោយ ពីក្នុងស្មៅក៏ដោយ ស្រេចលើរូបឯងបេះធ្វើ ; យើងដឹងតែត្រូវឲ្យបានមេសេះទាំងនោះមក ទៅក្លាមទៅកុំតក់ទៀត" ។

ព្រះរាជធីតាទទួលព្រមហើយក្រាបថ្វាយបង្គំលាចុះមក ។ ព្រះនាងយកដំណឹងដែលទើបទទួលមកនេះ ទៅថ្លែងប្រាប់សុរ្យាបកា ។ ប្រាប់ថា: "សូមព្រះនាងជាម្ចាស់ទៅរកស្បែកក្របីប្រាំបួនលាបជ័រយ៉ាងស្អិត

ហើយយកមកគ្របលើខ្លួនទូលព្រះបង្គំ ។ សូមព្រះនាងកុំគិតភ័យឲ្យសោះ ដោយអាស្រ័យការជំនួយនៃព្រះជាម្ចាស់ ព្រះនាងគង់នឹងអាចញ៉ាំងការៈនេះឲ្យសម្រេចបានជាមិនខាន ។ ប៉ុន្តែសូមព្រះនាងទ្រង់ជ្រាបចុះថា: ព្រះចៅកជាធិកដគង់តែត្រូវបង់ខាតជាយ៉ាងខ្លាំង ដោយសារតែកិរិយាមារយាទមិនសុចរិតនៃព្រះអង្គដែរ ” ។

ព្រះនាងទៅធ្វើតាមតែកដអស្សពោហាន់បង្គាប់ ហើយក៏នាំគ្នាចេញទៅ ។ ខាងក្រោយការធ្វើដំណើរយ៉ាងឆ្ងាយនឹងយ៉ាងវេទនា ជនទាំងពីរបានដល់ឆ្នេរសមុទ្រដែលហ្វូងសេះញីកំពុងស៊ីស្មៅនៅនោះ ។ ព្រះនាងទៅទ្រង់បានជួបនឹងយក្ស ដែលជាអ្នកលួចឆក់ទូវនាងអ៊ឡេណា-សិម្យ៉ាណាលើកមុន កំពុងតែដើរចុះដើរឡើង ដូចមនុស្សឆ្កួត ដើម្បីស្វែងរកហ្វូងមេសេះ ។ លុះបានដំណឹងថា នាងអ៊ឡេណា-សិម្យ៉ាណា គេលួចដណ្ដើមយកពីវាទៅទៀតហើយ ។ ម្ដាយវាបានដល់នូវសេចក្ដីមរណៈដោយការឈឺចិត្ត ព្រោះតាមអ្នកលួចមិនទាន់ យក្សនុះឯងគិតតែពីព្រួសអណ្ដាតភ្លើង ពាសវាលពាសកាល ដោយចិត្តក់ហឹងតាមតែស្ទាប់អាណាក៏ដោយ ។ ហើយកាលណាដឹងថា អ្នកលួចនាងអ៊ឡេណា-សិម្យ៉ាណា មកនៅចំពោះមុខវា សេចក្ដីក្រោធនឹងសេចក្ដីទុក្ខធ្វើវាឲ្យវង្វេងស្មារតី ។ ស្រែកដូចសត្វសិង្ហ យក្សនុះស្ទុះហោតសំដៅព្រះរាជ-ធីតា ដែលជាក្សត្រីប្រកបដោយសតីរឹងប៉ឹងនឹងសេចក្ដីក្លាហានដ៏ឧត្ដម ។

ប្រយុទ្ធគ្នាលើកនេះរកអ្វីប្រៀបគ្មាន ៗ ព្រះរាជមនោម័យចាំជួយការពារព្រះនាងនឹងអាវុធយក្ស គឺថាកាលណាសេះឃើញយក្សបំរុងនឹងកាប់នាងហើយ ក៏ស្ទុះហោះទៅលើឲ្យផុតហួសសេះយក្ស ហើយអាវុធយក្សកាប់ត្រូវតែខ្យល់ ៗ ប៉ុន្តែបើកាលណា ព្រះនាងពៅលើកព្រះខ័នបំរុងហើយសុរ្យាបតាងាយសំរុកទន្ទិចសេះយក្សមួយរំពេច ម្ល៉ោះហើយអាវុធរបស់ព្រះនាងពៅកាប់ត្រូវបច្ចាមិត្រមិនដែលខាន ៗ ជនទាំងពីរច្បាំងគ្នាស្មើស្រែកប្រថពី ដើមឈើតូចធំនឹងគិរីបពិតទាំងឡាយ សឹងញាប់ញ័រផ្អើលអស់សត្វនានា អារក្ស ទេព្តា យក្ស គន្ធព្វ រត់ខ្ចាត់ខ្ចាយរកតែទីជ្រកវៀងខ្លួន ៗ មហាសាគរកើតជារលកបោកបែកផ្កាត្រែងនាគទាំងឡាយសឹងលិចលង់ មនុស្សទាំងឡាយដល់នូវសេចក្ដីស្លាប់ជាអនេក មច្ឆានឹងជលសត្វទាំងឡាយហែលមុជរកទីពឹងកន្លងសាកាយនឹងកន្ធរូបថស្មើរពុំទាន់ ៗ លុះទីបំផុតព្រះរាជធីតា ទ្រង់ផ្ជង់ព្រះកាយព្រាលែងស្ដេចអសុរាមួយព្រះខ័នជ័យត្រូវដាច់ក ៗ រូបទុកខ្មោចយក្សចោលឲ្យជាអាហារដល់ក្អែកនឹងត្មាត ហើយសេះនឹងព្រះនាងក៏បន្តដំណើរទៅទៀត ទើបស្ដេចបានដល់កន្លែងហ្វូងមេសេះទាំងឡាយ ៗ

ដល់ទីនោះ សេះប្រាប់ព្រះនាងឲ្យឡើងដើមឈើ ហើយលបចាំមើលពីចុងឈើ ៗ ព្រះនាងក៏ធ្វើតាម ៗ ខណៈនោះសុរ្យាបតាស្រែកកញ្ជ្រៀវបីដង, សេះញីទាំងប៉ុន្មានប្រមូលគ្នាមកជុំ ៗ មិនយូរប៉ុន្មាន

លេចសេះឈ្មោលមួយមក បែកពពុះមាត់សំពោង ស្រែកកញ្ជ្រៀវ ទាំងកំហឹង ផាយផាក់មកពីនាយ ៗ បានឃើញមេសេះទាំងឡាយរបស់ខ្លួននៅព័ទ្ធជុំវិញសុវណ្ណបកាដូច្នោះ សេះនុះផាយសំរុកផាក់គ្មានគិតគូរ ហើយការតយុទ្ធរវាងសេះឈ្មោលទាំងពីរ គាំងឡើងយ៉ាងស្វិតស្វាញ ៗ កាលណាសេះនោះខាំសុវណ្ណបកាគឺខាំត្រូវតែស្បែកគ្របី បើកាលណាសុវណ្ណបកាខាំសេះនោះវិញ គឺខាំត្រូវបំសាច់មែនៗ ៗ ការប្រខាំគ្នារវាងសេះទាំងពីរតាំងនៅអស់ពេលដ៏យូរ ៗ លុះទីបំផុតសេះព្រៃផាច់រយះរយាយឈាមផាបខ្លួន ហើយបរាជ័យ ៗ ចំណែកសុវណ្ណបកាឥតមានរបិតអ្វីបន្តិចឡើយ ដោយសារបុណ្យស្បែកគ្របី ៗ វេលានោះព្រះរាជធីតាទ្រង់ស្ដេចចុះពីដើមឈើ ដំរើសុវណ្ណបការកៀងហ្វូងសេះញីទាំងនោះទៅ ឯសេះឈ្មោលនោះបោលតាមក្រោយគេអង្គុយៗ ស្ទើរតែមិនរួច ៗ

ព្រះនាងពៅកៀងសេះទាំងប៉ុន្មានចូលក្នុងព្រះបរមរាជវាំង ហើយឡើងទៅក្រាបបង្គំទូលថ្វាយដំណឹងដល់ព្រះចៅរាជាធិរាជ ៗ នាងអីឡេណា-សិម្ប៉ាណា ចេញពីប្រាសាទមកហើយហៅសេះរបស់នាងតាមឈ្មោះរៀងខ្លួន ៗ គ្រាន់តែឮសំឡេងនាងអីឡេណា-សិម្ប៉ាណា សេះឈ្មោលនោះត្រៀងខ្លួនភ្លាម ហើយស្នាមរបួសទាំងឡាយក៏វិនាសបាត់អស់ ត្រឡប់ជាមានកម្លាំងដូចដើមវិញ ៗ

(មានត)

# រឿងសាមកុក

កណ្ឌទី ៩

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ចូឆូបែរមុខចេញហើយលើកដៃចង្អុលប្រាប់ថា ចូឆូជិះសេះលឿនតែទៅខាងណោះ ៗ លីប៉ោមិនបានសង្កេតគ្មានសង្ស័យគិតថាពិត ក៏បរសេះត្រឡប់ទៅខាងក្រោយ ៗ ចូឆូត្រេកអរណាស់ បរសេះវេះចេញទៅទិសខាងកើត ទើបជួបប្រទះនឹងតៀនអ៊ុយៗត្រេកអរ- ក៏នាំចូឆូឆ្កាទាហានចេញទៅដល់មាត់ទ្វារ ឃើញគំនរឧសដែលភ្លើងឆេះនោះនៅទទឹងផ្លូវ ភ្លើងក៏នៅរាលឆេះប៉មកំពែងល្វែងហោណាំងខ្លាំងឡើង ៗ តៀនអ៊ុយក៏យកខ្លួនចាក់ភ្លើងដែលឆេះគំនរឧសនោះចេញអស់ពីផ្លូវ ហើយនាំចូឆូស្ទុះទៅដល់មាត់ទ្វារ ៗ កាលចូឆូទៅដល់មាត់ទ្វារនោះ ទទួលភ្លើងឆេះរបេះធ្នឹមក្លោងទ្វារធ្លាក់

មកត្រូវជើងសេះដែលចូចជិះដួលទៅលើគំនរភ្លើងស្លាប់ ។ ចូចក៏ស្ទុះលោតប្រញាប់ផុតពីគំនរភ្លើង តែអាវនឹងសក់ពុកមាត់ចូចត្រូវអណ្ដាតភ្លើងឆាបឆេះពេញអស់ទាំងខ្លួនប្រាណ ចូចទាញកន្ទាក់ហែកអាវនោះបោះចោលទៅ ហើយយកដៃទាំងទ្វេងស្ទាបខ្ទំបោសលត់ភ្លើង ដែលឆេះសក់នឹងពុកមាត់នោះទាល់តែរលត់ ទើបរត់ចេញទៅផុតមាត់ទ្វារ ។

តៀនអ៊ុយមើលមកក្រោយឃើញដូច្នោះ ក៏ស្ទុះលោតពីលើសេះចុះមក ទទួលហៃហ្វូអៀនទៅទាន់ ក៏ជួយគ្រាហ៍នាំចូចឲ្យឡើងជិះសេះរបស់ហៃហ្វូអៀនទៅ ។

ខណៈនោះ ទាហានលីបោ៊ស្ទុះតាមទៅជាច្រើនណាស់ តៀនអ៊ុយនឹងហៃហ្វូអៀន ពមកការពារតទល់ទាល់តែទៅដល់មុខបន្ទាយ លុះព្រឹកឡើងក្រឡេកឃើញទាហានតូចធំដែលបាក់បែករត់ដែលមកបាន ក៏បបួលគ្នាទៅសួរចូចៗ អស់សំណើចសើចក្អាកក្អាយហើយថា គ្រានេះយើងខូចសេចក្ដីចេះអស់ បានជាខូចខាតសេនាទាហានជាច្រើន បើខ្លួនយើងនៅមិនទាន់ស្លាប់ទេ យើងត្រូវតែគិតសងសឹកលីបោ៊វិញឲ្យបាន ។

គុយកៃឆ្លើយថា បើលោកនឹងគិតសងសឹកលីបោ៊ត្រូវចំគិតឲ្យឆាប់ ៗ ចូចឆ្លើយតបថា ដែលលោកដាស់តឿនខ្លួនយើងដូច្នេះ ត្រូវណាស់, ឯកុំម៉ាឡេងនោះមានចំពោះតែផ្លូវដើរ យើងនឹងលើកទាហានទៅបង្កប់តាមច្រកភ្នំ ហើយនឹងឲ្យទាហានទាំងពួងដែលនៅក្នុងបន្ទាយនោះ

ស្មៀកសពាក់សធ្វើជាយំសោករលីកអាល័យយើងថា ក្មេងនេះពេលជាទម្ងន់ទុរន់ទុរណាស់ នាំមកដល់បន្ទាយវេលាណាក៏អនិច្ចកម្មទៅ បើកិត្តិសព្ទទាំងនេះ ដឹងទៅដល់លីប៉ោៗ នឹងកំរើកលើកទាហានមកវាយបន្ទាយយើងតាមផ្លូវក្នុងម៉ាឡេង នោះយើងត្រូវសម្ងំឲ្យស្ងៀម បើឃើញកងទ័ពមុខលើករំលងហួសទៅដល់មាត់ផ្លូវវេលាណា សឹមយើងលើកសេនាទាហានចេញវាយកាត់កងទ័ពលីប៉ោ យើងមុខជានឹងចាប់ខ្លួនលីប៉ោបានដោយងាយ ៗ គុយកែឆ្លើយថា ដែលលោកគិតនោះល្អណាស់ គ្មាននរណាស្មើបាន ៗ ខណៈនោះ បូឆ្ងបង្គាប់ទាហានទាំងពួងឲ្យស្មៀកសពាក់សហើយឲ្យនាំគ្នាយំសោកអាណិតថា បូឆ្ងក្មេងនេះលំបាកវេទនាលុះត្រាហ៍មកដល់បន្ទាយពេលយប់ ក៏ទទួលអនិច្ចកម្ម ដូច្នេះ ដើម្បីឲ្យកិត្តិសព្ទទាំងនេះឮទៅដល់ទាហានលីប៉ោ ៗ ទាហានទាំងពួងបាននាំគ្នាធ្វើតាម ៗ បូឆ្ងក៏រៀបចាត់ចែងទាហានឲ្យលើកទៅបង្កប់នៅក្នុងម៉ាឡេង ៗ

ឯទាហានលីប៉ោឮកិត្តិសព្ទថាបូឆ្ងស្លាប់ ក៏នាំយកដំណឹងនោះទៅប្រាប់លីប៉ោៗ បានស្ដាប់សំគាល់ក្នុងចិត្តថាពិតប្រាកដ ទើបថា “គ្រានេះមុខជាសមប្រកបតាមគំនិតរបស់យើងហើយ យើងនឹងលើកទៅវាយទាហានបូឆ្ងទុកជាកំឡាំង” ថាហើយលើកទ័ពទាំងអស់ទៅឲ្យដល់ក្នុងម៉ាឡេង ៗ ទាហានកងមុខនោះលើកកន្លងចេញទៅដល់មាត់ផ្លូវជិតបន្ទាយបូឆ្ង ៗ ឯបូឆ្ងឃើញបានការ ក៏ឲ្យអុជផាវជាសញ្ញាឡើង ហើយ

លើកទាហានចេញវាយស្កាត់ពាក់កណ្ដាលខ្ទប់ព័ទ្ធជុំវិញ ។ លីបោ៉ចេញទៅតទល់ដោយអង់អាចកណ្ដាលទ័ព ទាហានស្លាប់ខូចខាតជាច្រើន ។ លីបោ៉ក៏នាំទាហានដែលនៅសល់នោះ លើកពុះពារត្រឡប់ក្រោយចូលដល់ស្រុកបាក់អៀនវិញ ហើយបង្គាប់ឲ្យទាហានទាំងពួងឡើងត្រួតត្រារក្សាសើនបន្ទាយដោយមាំមួន ចំណែកប៉ូឆូលើកទាហានចូលបន្ទាយវិញ ។

ក្នុងសម័យនោះ អាណាខែត្រខាងទិសឯកើតកើតមានសត្វដង្កូវជាច្រើន ស៊ីអស់ស្រូវក្នុងស្រែទឹងស្ទឹមកណ្ដាប់គ្រប់ដែនដំបន់ ស្រូវឡើងថ្លៃ ១ ថាំង ៩ រៀល ។ អស់អាណាប្រជានុរាស្ត្រទាំងពួង ក្រខ្សត់អត់ឃ្លានដាច់ពោះស្លាប់ជាច្រើន ។ មនុស្សខ្វះកាប់សម្លាប់គ្នា អារយកសាច់មកបរិភោគជាអាហារ ។ ឯទាហានក្នុងកងទ័ពប៉ូឆូដាច់ស្បៀងអាហារយូរថ្ងៃ ប៉ូឆូទើបលើកទ័ពទៅបញ្ឈប់ក្នុងស្រុកអៀនសៀ ។ លីបោ៉ឃើញដូច្នោះ ក៏លើកទាហានចេញទៅរក្សាគយប្រទល់ដែនខែត្របាក់-អៀនគ្រប់ដំបន់ ។

# កណ្ឌទី ១០

ចាប់តាំងពីតោកៀមប្រឹក្សានឹងបិតុកថា ខែត្រឈីជីវនេះ យើងត្រូវប្រគល់ឲ្យឡៅពីគ្រប់គ្រង ។ លុះដល់តោកៀមអនិច្ចកម្មទៅ ខែត្រឈីជីវក៏បានមកឡៅពីគ្រប់គ្រងមែន ។ ចូឆ្វូខឹងចិត្តខ្លាំង ព្រោះមិនបានសម្លាប់តោកៀមដារ : វសងសឹក ទាំងឃើញស្រុកឈីជីវបានទៅឡៅពីកាន់កាប់ ដោយគ្មានស្រក់ឈាម ទើបរៀបកងទ័ពដោយបំណងនឹងទៅវាយឡៅពី . . . រៀងរហូតដល់លីប៉ោច្បាំងចាញ់ចូឆ្វូ ហើយទៅសុំនៅនឹងឡៅពី ។

---

*ពេលនោះ តោកៀមហៅហ្វាយស្រុកឈីជីវ អាយុ ៦៣ ឆ្នាំ មានជម្ងឺឈឺធ្ងន់ណាស់ ទើបឲ្យហៅបិតុកនឹងគាន់តេងមកប្រឹក្សាថា ខ្លួនខ្ញុំជរាហើយថែមទាំងមានជម្ងឺឈឺធ្ងន់ទៀត បើជាមានសឹកសាមមកមុខជានឹងធុតសង្ស្យមសោះ ។ បិតុកឆ្លើយថា ដែលលោកគិតដូច្នោះក៏ត្រូវហើយ ព្រោះខ្ញុំដឹងថា ទ័ពចូឆ្វូដែលលើកទៅច្បាំងនឹងលីប៉ោលើកនេះជាសេចក្ដីហ្មងហែង បានជាលីប៉ោលើកទ័ពទៅវាយយកស្រុកគុនជីវ ចូឆ្វូនឹងលីប៉ោច្បាំងគ្នាដូច្នេះទទួលស្រូវក៏ថ្លៃ បានជាចូឆ្វូលើកទ័ពទៅតាំងនៅស្រុកអៀនសៀ បើដល់ចូលឆ្នាំថ្មី ស្រូវអង្ករបរិបូណ៌ហើយ មុខជាចូឆ្វូនឹងលើកទ័ពមកធ្វើសង្គ្រាមនឹងលីប៉ោទៀត បើដូច្នេះសូមឲ្យលោកអញ្ជើញឡៅពីមក និយាយអង្វរលន់តួប្រគល់ស្រុកនេះឲ្យឡៅពីចុះ ពេលនេះប្រហែលឡៅពីព្រមទទួលមិនខាន បើបានដូច្នេះអស់បណ្ដាស្រុកក៏នឹងបានសេចក្ដីសុខតទៅ ។*

តោកៀមយល់ឃើញត្រូវ ក៏ឲ្យបំរើចេញទៅអញ្ជើញឡេវពីស្រុកសៀវផាយឲ្យចូលមក ។ ឡេវពីឃើញបំរើទៅប្រាប់ក៏ប្រញាប់រៀបខ្លួនចូលមកជាមួយនឹងកូនអ៊ូ គៀវហ៊ុយ ហើយចូលទៅរកតោកៀមៗក៏ឲ្យអញ្ជើញឡេវពីចូលទៅក្នុង ហើយនិយាយថា សព្វថ្ងៃខ្លួនខ្ញុំកាន់តែចាស់ជរាពេកពោធបង្កើតមានជាទម្ងន់ មិនដឹងជាសេចក្ដីស្លាប់នឹងមកដល់វេលាណាទេ ខ្ញុំមានតែសេចក្ដីបរិតក្កនឹងស្រុកឈីជីវនេះ ព្រោះមិនមានអ្នកឯណានឹងត្រួតត្រាក្សា បានជាឲ្យអញ្ជើញអ្នកមកប្រាថ្នានឹងលើកប្រគល់ឲ្យអ្នកៗ ចូរមានសេចក្ដីអាសូរករុណាដល់ខ្ញុំ ទទួលយកត្រាសម្រាប់ងារចុះ ដើម្បីនឹងបានជួយទំនុកបំរុងបណ្ដាព្រស្ដអ្នកស្រុកឲ្យបានសេចក្ដីសុខតទៅ ។ ឡេវពីតបថា លោកមានបុត្រាពេញការទាំងពីរនាក់គឺតោស៊ីងជាបង តោអេងជាប្អូន ហេតុម្ដេចមិនប្រគល់ការពជការក្នុងស្រុកនេះជាជំនួសលោក? ។ តោកៀមឆ្លើយថា បុត្រខ្ញុំទាំងពីរនេះល្ងង់គ្មានសតិប្បញ្ញាសោះ បើនឹងប្រគល់ឲ្យកាន់ការឃើញថាធ្វើមិនកើត យូរទៅគង់នឹងមានទុក្ខដល់អាណាប្រជានុរាស្ដ្រមិនខាន ខ្ញុំឃើញតែអ្នកនឹងទទួលការបានៗ ជាឲ្យអញ្ជើញមក, បើខ្ញុំអស់ជីវិតវេលាណា កុំឲ្យអ្នកប្រគល់ការឲ្យបុត្រាខ្ញុំទាំងពីរនេះឡើយ ។

ឡេវពីឆ្លើយថា ខ្លួនខ្ញុំក៏ទ្បាំងតិចណាស់ ដែលនឹងទទួលធ្វើជាចៅហ្វាយស្រុកនេះ ឃើញថានឹងផុតឥតសង្ឃឹមសោះ ។ តោកៀម

ថា "ទាហានក្នុងស្រុកនេះមានច្រើន ខ្ញុំនឹងឲ្យស៊ុនខៀនទៅហ្វាយស្រុក បាក់ហៃមកជាទីប្រឹក្សាផង" ដូច្នេះហើយនិយាយនឹងបិតុកថា ប៉េឡៀតី ទទួលធ្វើជាចៅហ្វាយខេត្តតទៅ ឲ្យអ្នកទៅផ្ញើខ្លួនធ្វើរាជការជាមួយនឹង ឡៀតីចុះ ។ ឯឡៀតីក៏នៅមិនទាន់ទទួលពាក្យគោកៀមថាម្ដេច ។

ខណៈនោះ ពេកគោកៀមកាន់តែបណ្ដាលកំរើបឡើង នឹងចរចាក៏ពុំបាន យកតែម្រាមដៃបង្អុលត្រង់ខ្លួនហើយដាច់ខ្យល់ស្លាប់ ។ សេនាទាហានគោកៀមទាំងប៉ុន្មាន ក៏លើកយកត្រាសម្រាប់ងារមកប្រគល់ឲ្យឡៀតី។ មិនព្រមទទួល ។ សម័យនោះ បណ្ដាអ្នកស្រុកក្នុងទីចំណុះខេត្តបានដឹង នាំគ្នាចូលមកគំនាប់ឡៀតីហើយនិយាយអង្វរលន់តួថា ដែលលោកមិនព្រមទទួលធ្វើជាចៅហ្វាយខេត្តឈីជីវនេះ អំណើះតទៅយើងខ្ញុំទាំងឡាយនឹងបានសេចក្ដីទុក្ខក្ដៅខ្លាំងណាស់ ។ កួនអ៊ូ តៀវហ៊ុយ ឃើញដូច្នោះក៏ជួយនិយាយទៀត ដោយហេតុមានចិត្តអាណិតអាសូរអាណាប្រជានុរាស្ត្រពន់ប្រមាណថា សូមឲ្យលោកទទួលយកត្រាធ្វើចៅហ្វាយខេត្តឈីជីវ ។ ឡៀតីបានស្ដាប់ពាក្យ កួនអ៊ូ តៀវហ៊ុយ ក៏ព្រមទទួលត្រាក្នុងខណៈនោះ ហើយតាំងស៊ុនខៀននឹងបិតុកទុកជាទីប្រឹក្សាឆ្វេងស្ដាំ, ឲ្យកួនអ៊ូ តៀវហ៊ុយទៅឈររក្សាស្រុកសៀវផាយ ហើយនាំយកទាហានចូលមកក្នុងស្រុកឈីជីវទាំងអស់ ។ ឡៀតីនឹងសេនាទាហាននៅអស់បណ្ដារាស្ត្រក្នុងស្រុកនោះ ក៏ស្រុះស្រួលបបួលគ្នា

ស្លៀកពាក់សកាន់ទុក្ខ ហើយឲ្យរៀបតែងការសពគោកៀមតាមទំនៀម រូបនាំយកសពនោះដង្ហែទៅបញ្ចុះទុកនៅតំបន់អុយហោ ។ ឡៅតីរើយកសំបុត្រដែលគោកៀមធ្វើទុកនោះ មកប្តឹងចូលទៅស្រុកក្រុងឲ្យយកសេចក្តីក្រាបបង្គំទូលព្រះចៅហៀនតេ ។ ក្នុងសេចក្តីសំបុត្រនោះថា: “គោកៀមមានអាការដកភាព ទើបលើកខែត្រឈើជីវប្រគល់ឲ្យឡៅតីធ្វើរាជការជំនួស” ។ ព្រះចៅហៀនតេជ្រាបសេចក្តីហើយ ក៏មិនបានត្រាស់ថាប្រការម្តេច ។

ឯចូធូនៅស្រុកអៀនសៀឮដំណឹងថា គោកៀមចៅហ្វាយខែត្រឈើជីវអនិច្ចកម្ម, ឡៅតីបានធ្វើជាចៅហ្វាយខែត្រនោះ ដូច្នេះហើយខឹងណាស់ថា “យើងមានសេចក្តីក្តៅក្រហាយនឹងគោកៀម ព្រោះមិនទាន់បានសងសឹកគោកៀមសោះ ស្រាប់តែវាអស់ជីវិតទៅ, ឯឡៅតីនោះសោតក៏មិនបានធ្វើសឹកសង្គ្រាម ឲ្យខូចខាតទាហាននឹងព្រួញធ្នូ១ឡើយ ហើយមកបានជាចៅហ្វាយស្រុកស្រណុកដោយងាយ ដូច្នេះ យើងនឹងលើកទ័ពទៅសម្លាប់ឡៅតីចេញហើយលើកសពគោកៀមឡើងវិញ ចំព្រាំឲ្យល្អិតសាច់នឹងឆ្អឹង ទើបនឹងអស់សេចក្តីក្តៅ” ថាហើយក៏តាំងចាត់ចែងកេណ្ឌកងសេនាទាហានលើកទៅស្រុកឈើជីវ ។

ស៊ិនហុកទីប្រឹក្សាឃើញដូច្នោះ និយាយហាមឃាត់ចូធូថា ដែលលោកនឹងលើកទ័ពទៅវាយយកស្រុកឈើជីវនោះ, ជាការកម្រណាស់

មួយរយនាក់ទើបគិតការនេះបានម្នាក់ ដូចកាលគ្រាព្រះចៅហាន់កោចោ នឹងព្រះរាជវង្សបានសោយរាជ្យតជាលំដាប់គ្នាមកដល់ ១២ ព្រះអង្គ, ទទួលអងម៉ាំងគិតក្បត់ បានរាជសម្បត្តិដល់ ១៨ ឆ្នាំ, ហាន់កងប៊ូជាក្មួយព្រះមហាក្សត្រដែលខូចរាជសម្បត្តិដល់អងម៉ាំងនោះ ក៏សម្លាប់អងម៉ាំងចេញ បានរាជសម្បត្តិមកវិញ បានសោយរាជ្យជាដំណទៀតចំនួន ១២ ព្រះអង្គ ទើបដល់ព្រះចៅហៀនតេ, ឯសព្វថ្ងៃនេះ បើលោកនឹងគិតការធំទៅមុខក៏ប្ដូររកទំនុកទុកឲ្យមាំដូចព្រះមហាក្សត្រពីដើម ទើបនឹងគិតការតទៅបាន ឥឡូវលោកនឹងលើកទ័ពទៅវាយស្រុកឈីជីវតែម្ដងនោះ ខ្ញុំឃើញថារាស្ត្រទាំងពួងនៅមានចិត្តស្រឡាញ់ឡៅពីច្រើន ឃើញថានឹងវាយយកស្រុកនោះមិនបានដោយងាយទេ ឯស្រុកអៀនសៀ បើលោកឲ្យទាហានទៅរក្សានោះ លីប៉ោ៎ដឹងហើយក៏នឹងលើកទ័ពមកវាយយកទទេសោះ លោកលើកទៅខាងណោះបើមិនកើតការ នឹងត្រឡប់មកខាងណាក៏មានតែបាញ់ប្រៀបទាំងសងខាង ថែមទាំងខូចខាតទាហានគ្មានទីអាងម្ល៉េះហើយលោកក៏នឹងតាំងខ្លួនពិបាកណាស់, ទំរាំនឹងដុះក្រាស់ហើរបានឡើងវិញក៏យូរទៅមុខ, ដែលលោកនឹងលះបង់ស្រុកទូលាយហើយទៅរកទីចង្អៀតវិញ នោះសូមឲ្យលោកត្រិះរិះមើលដោយគួរសមសិន ។

ចូចូតបថា អាណាខែត្រខាងប៉ូពាទ័ស សុទ្ធតែមនុស្សទុរ្ភិក្សអត់ឃ្លានដោយស្បៀងអាហារ ដែលនឹងឲ្យរង់គិតការតទៅក៏នៅក្នុងព្រួយលំបាក ព្រោះទាហានយើងមុខជាត្រូវអត់ឃ្លានស្បៀងអាហារស្លាប់ពុំខាន ។

ស៊ិនហុកឆ្លើយថា ឥឡូវនេះខ្ញុំដឹងដំណឹងថា ហោងីទឹងអ៊ុយសៀវ ឃុំនាំពួកចោរដួតក្បាលល្បឿងទៅនៅស្រុកអេងជីវ ភតក្បាតធ្វើទុកបុកម្នេញដល់អាណាប្រជានុរាស្ត្រខ្ទាំងណាស់, បើលោកលើកទ័ពទៅវាយ. ពួកចោរនោះបែក ក៏នឹងបានស្បៀងអាហារមកជប់លៀងសេនាទាហាន រាស្ត្រទាំងពួងក៏នឹងមានអំណរចុះចូលមកតឹងតរៈលោកមិនខាន ហើយបើផ្ដាប់សេចក្ដីនោះទៅដល់ព្រះចៅហៀនតេទៀត ក៏នឹងបានសេចក្ដីគាប់ប្រសើរដល់លោក ។ ប៊ូច្ចបានស្ដាប់ឃើញត្រូវ ក៏ឲ្យទៅប្រាប់ហៃហ្វុនទឹងចោយិននៅរក្សាស្រុក ឯខ្លួនប៊ូច្ចឯងក៏បបួលសេនាទាហានលើកទៅស្រុកអេងជីវ ។

ខណៈនោះ ហោងីទឹងអ៊ុយសៀវជាមេចោរបានដឹង ក៏លើកពួកចោរទៅបោះទ័ពនៅតំបន់ភ្នំអេងសាន់ ។ ប៊ូច្ចដើរចេញទៅមើលពួកកងទ័ពចោរឃើញរបៀបខុសក្បួនសឹក ក៏ឲ្យតៀនអ៊ុយលើកទាហានទៅច្បាំងនឹងពួកចោរ ។ ហោងីក៏ឲ្យទាហានចេញតទល់នឹងតៀនអ៊ុយបាន ៣ ភ្លេង, តៀនអ៊ុយយកខ្លួនចាកទាហានប៊ូច្ចធាក់ពីលើសេះស្លាប់ ។ ប៊ូច្ចក៏បរពលចូលប្រកាប់ពួកចោរ ទំលាយបន្ទាយនៅភ្នំនោះបែកខ្ចាត់ខ្ចាយ ហើយតាំងបោះទ័ពនៅទីនោះ លុះវេលាព្រឹកឡើង អ៊ុយសៀវក៏លើកទាហានចេញមកដល់បន្ទាយប៊ូច្ច ។

ហោប៉ាន់ទាហានចោរមានកំឡាំងខ្លាំង កាន់ដំបងដែកចេញមកមុខទាហានហើយស្រែកប្រកាសថា នរណានឹងតស៊ូគ្នាក៏ឲ្យប្រញាប់ចេញមក ៗ ចោហងបានឮក៏កាន់ដាវចូលទៅប្រយុទ្ធគ្នានឹងហោប៉ាន់បាន ៥ ក្បួន ចោហងធ្វើជាថយរត់ទៅក្រោយ ហោប៉ាន់គ្រវែងដំបងចោលសំដៅទៅចោហង ៗ គេចផុត ស្ទុះចូលមកកាប់ហោប៉ាន់ដាច់ពាក់កណ្តាលខ្លួនស្លាប់នៅទីនោះ ៗ លីតៀនឃើញដូច្នោះ ក៏បរសេះកំខ្លួនដេញកាប់ពួកចោរចូលទៅចាប់ខ្លួនអ៊ុយសៀវបាន ៗ ចូចូក៏លើកទាហាន តាមចូលទៅដល់បន្ទាយចោរ ៗ ក៏រត់ព្រាត់ព្រាយខ្ចាត់ខ្ចាយអស់ទៅ ទាហានចូចូក៏ប្រមូលរើសយកទ្រព្យរបស់ចោរបានជាច្រើន ៗ

ហោធីមេចោរនាំពួកកៀនប្រមាណ ២០០ ប៉ាយរត់ចេញពីបន្ទាយទៅដល់ភ្នំ ១ ក្រឡេកឃើញខៅធូជិះសេះកាន់ដាវឈរទាំងផ្លូវ ៗ ហោធីបំផាយសេះចូលប្រយុទ្ធនឹងខៅធូបាន ១ ក្បួន ខៅធូចាប់ហោធីបាន ៗ ឯពួកចោរទាំងប៉ុន្មានក៏ចុះចូលមកជាពួកខៅធូទាំងអស់ ខៅធូនាំហោធីនិងពួកចោរចូលទៅនៅក្នុងរូងភ្នំ ដែលធ្លាប់នៅសំណាក់ ៗ ចូចូឃើញហោធីរត់ទៅដូច្នោះក៏ឲ្យតៀនអ៊ុយតាមទៅចាប់ខ្លួន ៗ តៀនអ៊ុយបរសេះលើកទាហានទៅដល់ជើងភ្នំ ឃើញខៅធូនាំពួកម៉ាកចេញមកឈរស្កាត់ទទឹងផ្លូវ ៗ តៀនអ៊ុយសួរថា អ្នកនេះជាពួកចោរដួតក្បាលលឿងឬ? ៗ ខៅធូតបថា យើងមិនមែនពួកចោរទេ, ឯពួកចោរដួត

ក្បាលលឿងនោះយើងចាប់បានមេហ៉ម្នាក់មកទុកក្នុងរូងភ្នំ ។ តៀនអ៊ុយសួរថា បើដូច្នោះ ចូរអ្នកទៅយកពួកចោរនោះមកឲ្យយើងជាធាប់ ៗ ខៅជូឆ្លើយថា បើអ្នកយកក្បាលវង់ទទួលដាវយើងនេះបាន ទើបយើងប្រគល់ពួកចោរឲ្យ ។ តៀនអ៊ុយឮសំដីដូច្នោះ ក៏ខឹងណាស់ បរសេះរំដាវចូលទៅ ប្រយុទ្ធនឹងខៅជូតាំងពីព្រឹកលុះដល់ថ្ងៃត្រង់មិនចាញ់មិនឈ្នះ, ទាំងសងខាងក៏ថយឈប់សម្រាកកម្លាំង ហើយក្រោកឡើងបបួលគ្នាប្រយុទ្ធទៀតតាំងពីថ្ងៃត្រង់ដល់រសៀលល្ងាច សេះក៏អស់កំឡាំង ខៅជូនឿយណាស់វិលចូលទៅក្នុងរូងភ្នំវិញ ។ តៀនអ៊ុយឲ្យទាហាននាំយកសេចក្ដីទាំងនោះទៅប្រាប់បូឆូៗ បានដឹងដូច្នោះលើកទាហានចេញទៅទាំងពេលយប់ ។

លុះពេលព្រឹកព្រហាមខៅជូនាំបក្ខពួកចេញពីក្នុងរូងភ្នំ ។ បូឆូឃើញរូបរាងខៅជូមាឌធំខ្ពស់ប្រហែល ៦ ហត្ថសមជាទាហាន ក៏គិតចង់បានខៅជូទុក ។ ទើបបង្គាប់តៀនអ៊ុយថា អ្នកចូរទៅតយុទ្ធម្ដងទៀត ហើយធ្វើជាថយរត់ត្រឡប់មកក្រោយវិញ ។ តៀនអ៊ុយក៏ធ្វើតាម លុះប្រយុទ្ធគ្នាបាន ៣០ ក្លង ក៏ថយត្រឡប់មកក្រោយដោយរហ័ស, ខៅជូក៏បំផាយសេះដេញតាម, បូឆូឃើញដូច្នោះបង្គាប់ឲ្យទាហានបាញ់ធ្នូចម្រុះទៅ ខៅជូឃើញកម្លាំងនឹងតទល់ពុំបាន ញាក់សេះបរត្រឡប់នាំបក្សពួករួលទៅក្នុងរូងភ្នំវិញ ។ លុះដល់វេលាអាធ្រាត្រស្ងាត់ បូឆូ

បង្គាប់ឲ្យជីករំលុង ហើយយកអន្ទាក់ដាក់នៅមាត់រំលុងនោះ ហើយយកស្មៅពយដាក់ពីលើមាត់រណ្ដៅមិនឲ្យស្គាល់បាន ។ ដល់ព្រឹកព្រាងឡើង ចូចូក៏ចាត់តៀនអ៊ុយឲ្យលើកទាហាន ១០០ ចូលទៅស្រែកដេរដៀមដាមនៅមាត់រូង បើឃើញខៅជូចេញមកឲ្យតទល់បញ្ឆោតថយមកត្រង់រំលុងនោះ ។ តៀនអ៊ុយលើកទាហាន ១០០ ទៅធ្វើតាមចូចូបង្គាប់ ខៅជូបានឮលើកបក្សពួកចេញមក ឃើញទៀនអ៊ុយហើយស្រែកថា "អាទាហានជិះសេះនេះនឹងមកលេងគ្នានឹងអញទៀតឬ?" ហើយក៏បរសេះចូលទៅប្រយុទ្ធនឹងតៀនអ៊ុយបាន ១០ ក្វេង ទៀនអ៊ុយធ្វើជាញាក់សេះថយរត់ទៅខាងរំលុងនោះ ខៅជូមិនដឹងកលឧបាយបំផាយសេះដេញតាមទៅ សេះនោះក៏ផុងធ្លាក់ក្នុងរំលុងជាមួយនឹងខៅជូ អន្ទាក់នោះជាប់ជើងខៅជូជាមួយនឹងពួកម្នាក់ ទាហានចូចូក្រទាក់ខ្សែទុក ហើយចូលទៅឡោមព័ទ្ធចាប់ជើងដៃខៅជូចង នាំទៅឲ្យចូចូ ។ ឃើញដូច្នោះក៏ធ្វើជាភ្ញាក់ខ្លួន ហើយក្រោកចុះទៅស្រាយចំណងពីជើងដៃខៅជូចេញអស់ ឲ្យយកសំលៀកបំពាក់យ៉ាងល្អមកឲ្យខៅជូស្លៀកពាក់ ហើយទាញដៃមកឲ្យអង្គុយហើយសួរថា អ្នកឯងឈ្មោះអ្វី? កំណើតនឹងទីលំនៅនៅស្រុកណា? ហេតុម្ដេចទើបមកនៅនឹងរូងភ្នំ? ។

(មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យនគរធំ

### ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តទៅ)

## ព្រះបាទឥន្ទ្រវរ្ម័នទី ២

ព.ស. ១៧៤៨ - ១៧៨៨ (១) គ.ស. ១២០៥ - ១២៤៥

ព្រះបាទឥន្ទ្រវរ្ម័នទី ២ ជាព្រះរាជបុត្ររបស់ព្រះបាទជ័យវរ្ម័នទី ៧ នឹងព្រះនាងជយរាជទេវី អគ្គមហេសី ។ កាលនៅកុមារគេហៅព្រះនាម "លក្ខេយេស" ក៏មាន "ស្រីវីរិន្ទ្រកុមារ" ក៏មាន, កាលទ្រង់បានសោយរាជ្យ គេថ្វាយព្រះបរមនាមជា "ព្រះបាទឥន្ទ្រវរ្ម័ន" រាប់ជាទី ២, ទ្រង់មានព្រះអគ្គមហេសី ព្រះនាមដូចម្ដេច នឹងមានព្រះរាជបុត្រព្រះរាជធីតាឬទេ មិនអាចដឹងបាន ។

ការផែនដី — ព្រះបាទឥន្ទ្រវរ្ម័នទី ២ ទ្រង់មានព្រះសមត្ថភាពនឹងព្រះរាជចរិយាវត្ត ប្រហែលនឹងព្រះបរមរាជបិតា ទាំងព្រះរូបក៏ទ្រង់ស្វាហាប់យ៉ាងព្រះបរមជនកនាថ កាលនៅកុមារ ក្នុងពេលដែលព្រះរាជបិតាទៅគង់នៅក្រុងចាម្ប៉ា ទ្រង់បានជួយច្បាំងព្រះបាទយសោវរ្ម័នទី ២

---

១ ក្នុងប្រវត្តិសាកលថៃថា ព. ស. ១៧៤៤ - ១៧៦៣ ។

កម្រាបករតកហុ ដែលមកដណ្តើមរាជបល្ល័ង្ករបស់ព្រះបាទយសោវរ្ម័ន បាននូវជ័យជំនះ ក្រោយនោះមកទ្រង់បានច្បាំងតស៊ូនឹងពួក ព្រះត្រីកវនាទិត្យ ដែលក្បត់ព្រះបាទយសោវរ្ម័ន ទី ២ ទៀត តែគ្រានេះទ្រង់មិនអាចយកជ័យជំនះបាន សត្រូវបានលុកចូលក្នុងព្រះបរមរាជវាំង ធ្វើគតព្រះបាទយសោវរ្ម័នបង់ ។ កាលព្រះរាជបិតាបានសោយរាជ្យហើយ ព្រះស្រីវិន្ទ្រកុមារ បានម្រង់តំណែងជាមេទ័ពចេញច្បាំងកម្រាបចាម្ប៍ ជាមួយនឹងព្រះរាជបិតាដែលជាអគ្គសេនាប្រមុខ ជួបជល់មានជ័យជំនះយ៉ាងធំ ៗ ដោយទ្រង់មានសគុណបំណាច់យ៉ាងនេះ ព្រះបាទជ័យ-វរ្ម័ន ទី ៧ ទើបទ្រង់សាងប្រាសាទបន្ទាយឆ្មារនៅក្នុងខេត្តកំពង់ចាម្ប៍ ទុកជាអនុស្សាវរីយ៍ ដល់ព្រះអគ្គស្រីវិន្ទ្រកុមារ ។

កាលទ្រង់បានសោយរាជ្យឡើងហើយ ទ្រង់បានគ្រប់គ្រងរក្សាព្រះអាណាចក្រ នឹងអាណានិគម ឲ្យគង់នៅដូចដើម ។

លុះមកដល់ ព. ស. ១៧៤៦ ព្រះបាទឥន្ទ្រវរ្ម័នទ្រង់លើកទ័ពទៅកម្រាបចាម្ប៍ ដែលកើតទូរយសបះបោរមកតាំងពីក្នុងឆ្នាំ ១៧៣៦ បានសម្រេច ចាម្ប៍ធ្លាក់មកជាអាណានិគមខ្មែរយ៉ាងដើមវិញ ។ កាលស្រេចការកម្រាបនៅចម្ប៉ាហើយ ទ្រង់លើកទ័ពឡើង ទៅកម្រាបកៅដី (យួន) ទៀត ដោយហេតុពួកយួននេះ តែងរុករានទៅតាមជាយព្រះរាជ-អាណាចក្រ ប៉ែកខាងលើនោះជាញឹកញយ ៗ ន័យ ១ ទៀត ក្នុងពេល

នោះ មានកើតទុរយស ដោយមានសេនាបតីយួន ១ នាក់បង្កហេតុក្បត់ ផែនដីយួនផង ទ្រង់លើកកងទ័ពចូលវាយលុករហូតទៅដល់ខែត្រងើអាន ហើយ ទើបលើកទ័ពត្រឡប់មកកាន់វៀងចន្ទន៍ ហ្លួងព្រះបាង ដែលជាអាណានិគមមួយ, ទ្រង់កម្រាបពួកណាដែលបង្កហេតុបះបោរ ឲ្យរាបទាប ហើយស្តេចលើកទ័ពត្រឡប់ព្រះមហានគរ ដោយសុវត្ថិភាព ។

មកដល់ ព.ស. ១៧៩០ ក្សត្រិយ៍ប្រទេសចិន បានតែងរាជទូត ឲ្យនាំរាជសារនឹងរាជបណ្ណាការ មកសុំចងសម្ពន្ធមេត្រីភាពជាមួយនឹងប្រទេសកម្ពុជា ។ ខាងប្រទេសកម្ពុជា ក៏ព្រមទទួលសម្ពន្ធមេត្រីភាពនេះ យ៉ាងរាក់ទាក់ ។ ប្រទេសចិននឹងប្រទេសកម្ពុជា បានចងជាសម្ពន្ធមិត្រផងគ្នា ទៅវិញទៅមកតាំងពីក្នុងសម័យនគរភ្នំ រហូតជាគ្រាទី ៧ ក្នុងរជ្ជកាលនេះ ។

លុះមកដល់ ព.ស. ១៧៦៣ មិនដឹងជាដោយហេតុអ្វី ស្រាប់តែប្រាកដថា ប្រទេសកម្ពុជាបោះបង់ចោលចម្ប៉ា បណ្តោយឲ្យតាំងខ្លួនជាឯករាជ្យឡើងវិញ ។ តអំពីនោះមក ចាម្បលែងបានមកនៅក្នុងអំណាចត្រួតត្រាខ្មែរហើយ តែឯករាជ្យរបស់ចាម្ប ក៏មិនស្ថិតស្ថាពរដែរ ព្រោះក្រោយនោះមិនយូរប៉ុន្មាន ត្រូវពួកយួនកំទេចអស់រលីង ដែនចម្ប៉ាក៏ធ្លាក់ទៅជាសម្បត្តិរបស់យួន ជាតិចាម្បគោងខ្ចាត់ខ្ចាយទៅជ្រកនៅតាមប្រទេសទាំងឡាយក្នុងទ្វីបអាស៊ី មានប្រទេសកម្ពុជាជាដើម ដរាបមកដល់សព្វថ្ងៃនេះ ។

ប្រវត្តិសាស្ត្រ របស់ចាម្ប៍ដែលគួរនាំមកពណ៌នាក្នុងទីនេះ គឺជាជាតិអ្នកចំបាំងដ៏ក្លាហាន១ ហើយតាំងខ្លួនជាគូសត្រូវនឹងជាតិខ្មែរ នៅជិតខ្មែរ តែមិនដែលសុំចងសម្ពន្ធមេត្រីភាពយ៉ាងចិន មានតែលើកទ័ពមករាយប្រទេសកម្ពុជាញឹកញយ ដូចមានប្រាកដក្នុងប្រវត្តិសាស្ត្រស្រាប់ ទាំងនេះ ដោយអំណាចសេចក្ដីប្រុសប្រានឹងសេចក្ដីលោភចង់បានមហាភោគទ្រព្យរបស់ខ្មែរទៅជាសម្បត្តិរបស់ខ្លួន តែអំពើចចើងនេះ ទំនងដូចជាមមាចចូលភ្លើង ។

**ការព្រះសាសនា** – ព្រះបាទឥន្ទ្រវរ្ម័ន ទ្រង់កាន់ព្រះពុទ្ធសាសនាតាមយ៉ាងព្រះរាជបិតា នឹងព្រះរាជជននីនាថ ការកសាងវត្តស្ថានប្រហែលជាទ្រង់បានសាងទុកខ្លះដែរ តែមិនប្រាកដឈ្មោះប៉ុណ្ណោះ ។

មកដល់ឆ្នាំ ព. ស. ១៧៨៦ ព្រះបាទឥន្ទ្រវរ្ម័នទី ២ សោយទិវង្គតនៅក្រុងស្រីយសោធរបុរៈ គេថ្វាយព្រះនាមព្រះបរមសព្វដូចម្ដេចមិនប្រាកដ ។ ព្រះមហាក្សត្រិយ៍អង្គនេះរាប់ជា រាជាធិរាជ ១ ក្នុងប្រវត្តិសាស្ត្រ ។

## ព្រះបាទជយវរ្ម័នទី ៨

**ព. ស. ១៧៨៨ ១៨៣៨-៩, គ. ស. ១២៤៤-១២៩៥-៦**

ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា តាំងអំពីដើមរហូតដល់ក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី ២ មានអាការប្រៀបដូចឡើងស្ពានគឺថាព្រះមហាក្សត្រិយ៍ទាំងឡាយ រមែងមានព្រះតេជានុភាពនឹងព្រះសមត្ថភាព

អាចគ្រប់គ្រងប្រទេស ឲ្យគង់នៅជាមហាប្រទេស មហាអំណាចជាដរាបមក បើទុកជាមានថ្លោះធ្លោយខ្លះ ក៏អាចកែខ្លួនឡើងវិញបានភ្លាមៗ ។ លុះមកដល់កន្លងបុងសម័យនគរធំគឺពីត្រីមរដ្ឋកាល ព្រះបាទជយវរ្ម័នទី ៨ នេះទៅ ប្រទេសកម្ពុជាមានអាការប្រៀបដូចចុះពីស្ពាន គឺអំពីនេះទៅ ប្រទេសកម្ពុជាសន្សឹមៗ ថយអានុភាពចុះដោយលំដាប់ កន្លងបំផុតក៏ធ្លាក់ទៅជាអនុប្រទេស ដូចជានឹងមានប្រាកដទៅខាងក្រោយ ។

ព្រះបាទជយវរ្ម័នទី ៨ អង្គនេះ មិនដឹងជាតវង្សអំពីព្រះមហាក្សត្រិយ៍អង្គណាជាប្រាកដទេ តាមផ្ទរសន្និដ្ឋានថាគង់ជាតវង្សមកអំពីព្រះបាទជយវរ្ម័នទី ៧ នោះឯង ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេចមិនប្រាកដ, មានព្រះរាជឱរសបុត្រទេមិនប្រាកដ, ប្រាកដតែថាទ្រង់មានព្រះរាជធីតា ២ អង្គ, មួយអង្គបានទៅព្រះបាទស្រីន្ទ្រវរ្ម័នទី ២ មួយអង្គទៀតបានទៅព្រះស្រីបតិន្ទ្រឥន្ទ្រាទិត្យ ក្សត្រិយ៍ថៃនៅសុខោទ័យ ។

មកដល់កន្លងឆ្នាំ ព. ស. ១៨០០ ព្រះបាទជយវរ្ម័នទី ៨ បានទ្រង់ព្រះមេត្តាប្រោសតែងតាំងក្សត្រិយ៍ថៃ ១ អង្គព្រះនាមឃុនផាមឿង ឲ្យជាស្តេចប្រទេសរាជ នៅក្រុងសុខោទ័យ គ្រប់គ្រងអាណានិគមខ្មែរភាគខាងទិសពាយ័ព្យជាដំបូង ។ មុននឹងបញ្ជាក់ពីហេតុផលដែលទ្រង់ព្រះមេត្តាប្រោសតាំងឃុនផាមឿងជាប្រទេសរាជ គួរពណ៌នាអំពីប្រវត្តិរបស់ជាតិថៃ (សៀម) ទុកកន្លងនេះដោយសង្ខេបផង ។

(មានត)

# រឿងអារក្សថ្លែងរឿងម្ភៃប្រាំ

## លោកសាង - សារ៉ាត លេខានុការ ក្រសួងហិរញ្ញវត្ថុ

*ប្រែពីភាសាបារាំងមកជាខ្មែរ*

(តទៅ)

---

កាលលោកអាចារ្យបានស្តាប់ព្រះឱង្ការរបស់ព្រះមហាក្សត្រ នឹងពាក្យរបស់រាជអាមាត្យទាំងអស់ហើយ ក៏យល់ថា: "ព្រះអង្គទ្រង់ខំខ្នះខ្នែងជាពន់ពេក ដើម្បីកុំឲ្យលោកធ្វើសមណធម៌បាន" ។ លុះយល់ដូច្នោះ លោកអាចារ្យក៏រត់ចេញផុតព្រះរាជធានី ហើយសម្លាប់កូននោះទៅ រួចត្រឡប់ទៅនៅកន្លែងព្រៃវិញ បានតាំងសីលដូចមុនទៀត ។ ចំនួនច្រើនថ្ងៃក្រោយមក ស្តេចទ្រង់ទិវង្គត ឯអ្នកធុតង្គក៏តាំងសីលតទៅ ។

ន័យរបស់រឿងនេះដូច្នេះ : មានជនបីនាក់ កើតពេលម៉ោងតែមួយ ក្នុងទីក្រុងតែមួយ គឺម្នាក់នោះកើតក្នុងវាំងស្តេច, ជនទីពីរកើតក្នុងផ្ទះអ្នកជំនួញលក់ប្រេង, ជនទីបីគឺអ្នកធុតង្គដែលបានទៅកើតក្នុងផ្ទះនាយស្វនឆ្នាំង ។ ជនទីមួយសោយរាជ្យនៅទីនេះ, កូនអ្នកជំនួញប្រេងសោយរាជ្យនៅក្នុងឋាននរក, កូននាយស្វនឆ្នាំងបានសាងសីល ។ ស្វនឆ្នាំងនេះបានសម្លាប់ឈ្មួញប្រេង រួចក្លាយទៅជាអារក្សមួយអាក្រក់ ដែលស្ថិតនៅក្នុងប៉ាឆា ព្យួរក្បាលចុះមកក្រោម នៅលើដើមឈើមួយ, ឥឡូវវាកើតទុក្ខមិនសុខចិត្តនឹងខ្លួនវាស្លាប់នេះ ។ បើប្រសិន

ណាអ្នកចៀសវាងរួចបាន អ្នកនឹងបានសោយរាជ្យ យើងប្រាប់អ្នកជាមុន ចូរអ្នកប្រុងប្រយ័ត្នចុះ ។ លុះនិយាយយ៉ាងដូច្នោះហើយ អារក្សក៏ចេញទៅ ព្រះរាជាក៏យាងចូលទៅក្នុងព្រះបរមរាជវាំងវិញ ។ លុះព្រឹកឡើង ព្រះអង្គទ្រង់យាងចេញមក ហើយទ្រង់បង្គាប់ឲ្យប្រជាជនប្រជុំគ្នា ។ ជនទាំងអស់ ទោះមន្ត្រីក្តី ស្ត្រីក្តី ក៏ចូលទៅគាល់ព្រះមហាក្សត្រ ហើយយកដង្វាយទៅថ្វាយដល់ព្រះអង្គ ។ ស្គរភ្លេងតូរ្យតន្ត្រី ក៏លាន់ឮរំពងឡើង ។ ព្រះរាជធានីទាំងមូលដំកល់នៅក្នុងសេចក្តីរីករាយសប្បាយជាពន់ពេក ដែលកាន់តែធំឡើងៗ ។ រូបស្តេចក៏ចាប់គ្រងរាជ្យសម្បត្តិដោយយុត្តិធម៌តទៅ ។

គេនិទានថា: ថ្ងៃមួយនោះ មានអ្នកធុតង្គម្នាក់ឈ្មោះសន្តស៊ិល (Shant-Shil) មកក្នុងព្រះបរមរាជវាំង បានកាន់ផ្លែឈើមួយក្នុងដៃយកមកថ្វាយព្រះមហាក្សត្រដោយខ្លួនឯង ។ អ្នកធុតង្គនោះលុះបានក្រាលកម្រាលរបស់ខ្លួនហើយក៏អង្គុយចុះ ។ កន្លងមួយម៉ោងក្រោយមកក៏ចេញទៅវិញទៅ ។ លុះអ្នកធុតង្គទៅបាត់ ព្រះមហាក្សត្រទ្រង់នឹកថា: "តើមិនមែនអ្នកធុតង្គដែលអារក្ស (démon) និយាយប្រាប់អញទេឬអ្វី" លុះទ្រង់ឆ្ងល់ក្នុងព្រះទ័យដូច្នោះទ្រង់ក៏មិនសោយផ្លែឈើនោះ តែទ្រង់មានព្រះបន្ទូលហៅនាយជំនិតព្រះអង្គមក ទ្រង់ប្រទានផ្លែឈើនោះទៅ ដោយទ្រង់ត្រាស់បង្គាប់ឲ្យយកទៅរក្សាទុកឲ្យស្រួល ។ ប៉ុន្តែអ្នកធុតង្គតែងត្រឡប់មករកព្រះអង្គជាដរាប ហើយបានថ្វាយផ្លែឈើមួយ ។ រៀងរាល់ថ្ងៃ ។

ថ្ងៃមួយនោះ ទ្រង់ស្តេចយាងទៅទតក្រោលកជពាជី ដោយមានអ្នកបំរើជាច្រើនហែហមជាបរិវារទៅផង ៗ អ្នកផុតង្គក៏យកផ្លែឈើមកថ្វាយព្រះអង្គទៀត ៗ ព្រះអង្គទ្រង់ទទួលផ្លែឈើមក ទ្រង់ក្រវាត់ហោលទៅលើអាកាស ' ប៉ុន្តែស្រាប់តែផ្លែឈើនោះ ធ្លាក់ពីព្រះហស្តព្រះអង្គទៅចំលើព្រះអង្គ ស្តេចក៏ទ្រង់ដួលទៅលើពសុធា ៗ មានស្វាមួយរើសយកផ្លែឈើនោះទៅបំបែក ស្រាប់តែជះត្បូងពេជ្រមួយគ្រាប់ដែលមានពន្លឺជាអស្ចារ្យ ទាល់តែព្រះមហាក្សត្រនិងមិត្រព្រះអង្គទាំងអស់ឡើងស្រឡាំងកាំងគ្រប់គ្នា ៗ ព្រះអង្គទ្រង់មានព្រះរាជឱង្ការទៅកាន់អ្នកផុតង្គថា: "ហេតុអ្វីបានជាអ្នកឲ្យត្បូងពេជ្រនេះមកយើង?" ៗ អ្នកផុតង្គឆ្លើយថា: បពិត្រព្រះមហាក្សត្រដ៏ឧត្តម! គម្ពីរបានចែងថា ;

"គេមិនត្រូវចូលទៅក្នុងវាំងស្តេច, ក្នុងផ្ទះអាចារ្យ, ក្នុងផ្ទះហោរា, ក្នុងផ្ទះពេទ្យឬក្នុងផ្ទះនារីក្រមុំណាដោយដៃទទេនោះទេ" អាស្រ័យហេតុនេះហើយ បានជាទូលព្រះបង្គំមកក្នុងទីនេះវេលាណា កាន់ផ្លែឈើមួយជានិច្ចមកផង សូមទ្រង់ព្រះមេត្តាប្រោស! តើព្រះអង្គមានព្រះរាជឱង្ការដល់គ្រាប់ពេជ្រតែមួយធ្វើអ្វី? ក្នុងពេលដែលទូលព្រះបង្គំយកផ្លែឈើមកថ្វាយទាំងអស់សុទ្ធតែមានត្បូងដ៏ថ្លៃថ្លា ៗ

លុះព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ទ្រង់បង្គាប់ឲ្យនាយជំនិតព្រះអង្គ យកផ្លែឈើទាំងអស់ដែលអ្នកផុតង្គថ្វាយរួចមកហើយ លុះ

បំបែកផ្លែឈើទាំងនោះទៅ កំឃើញមានគ្រាប់ត្បូងពេជ្រចេញមកគ្រប់ផ្លែឈើមែន ។

កាលទ្រង់ទតឃើញត្បូងទាំងអស់នោះហើយ ព្រះអង្គមានព្រះហឫទ័យរីករាយជាពន់ប្រមាណ ទ្រង់ត្រាស់ឲ្យហៅជាងថ្លៃមក ដើម្បីពិនិត្យមើលថ្លៃពេជ្រនោះ ហើយមានព្រះរាជឱង្ការទៅជាងថ្លៃថា: "យើងគ្មានបានយកអ្វីទៅផងទេក្នុងលោកនេះ, សេចក្ដីស្មោះត្រង់ជារត្នមួយធំបំផុតនៃស្ថានកណ្ដាលនេះ; ហេតុដូច្នេះ ចូរអ្នកនិយាយឲ្យត្រង់មើល តើថ្លៃនេះមួយៗ ដម្លៃប៉ុន្មាន?" ។ លុះស្ដាប់ព្រះរាជឱង្ការចប់ហើយ ជាងថ្លៃក្រាបទូលថា: "សូមទ្រង់ព្រះមេត្តាប្រោស! ព្រះអង្គទ្រង់មានព្រះរាជឱង្ការតាមផ្លូវពិត, ជនណាមានគុណធម៌ ជននោះគេទុកជាអ្នកមានបំផុត; គុណធម៌តែងដឹកនាំយើងទៅកាន់សេចក្ដីល្អជាដរាប គុណធម៌នេះជួយទ្រទ្រង់យើងក្នុងលោកទាំងពីរ; សូមក្រាបទូលទ្រង់ថ្លៃមួយៗនោះ មានពណ៌, ទម្ងន់ទ្រង់ទ្រាយនៅពេញជាល្អណាស់, បើប្រសិនជាទូលព្រះបង្គំថា ថ្លៃមួយៗថ្លៃ ១០ សែនកហាបណៈ នោះក៏នៅតែតិចជាងដម្លៃពិតរបស់ថ្លៃនេះ, ដោយពិតទៅ ថ្លៃមួយៗនេះថ្លៃស្មើមួយភាគក្នុងភាគ ៧ នៃពិភពលោកយើងនេះ ។

ព្រះករុណាលុះទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់មានព្រះហឫទ័យរសោមនស្សជាទីបំផុត ហើយទ្រង់ប្រទានអាវសក្ដិមួយទៅជាងថ្លៃនោះ

ទើបទ្រង់បង្គាប់ឲ្យចេញពីទីនោះទៅ ។ ព្រះអង្គទ្រង់ចាប់ដៃអ្នកចុតង្គ ហើយឲ្យអ្នកចុតង្គនោះអង្គុយក្រោមស្វេតច្ឆ័ត្រ រួចទ្រង់មានព្រះរាជឱង្ការថា: "ព្រះរាជអាណាចក្ររបស់ខ្ញុំទាំងមូល តម្លៃមិនស្មើនឹងត្បូងថ្មរបស់អ្នកមួយគ្រាប់ផង, សូមអ្នកប្រាប់ខ្ញុំ ហេតុម្តេចអ្នកនៅខ្លួនទទេ? ហេតុដូចម្តេច បានជាអ្នកឲ្យត្បូងថ្មនេះមកខ្ញុំ?" ។

— សូមទ្រង់ព្រះមេត្តាប្រោស! ទូលព្រះបង្គំនឹងទូលព្រះករុណាឲ្យទ្រង់ជ្រាប តែឥឡូវនេះមិនទាន់បាន ដ្បិតរឿងសិល្បសាស្ត្រ, រឿងសម្ភាសន៍, រឿងសាសនា, រឿងកង្វះ រឿងមិនគប្បីដូចជាការស្រេកឃ្លានដោយតណ្ហា, រឿងពាលទិទានដែលយើងបានព្រ ទាំងនេះគេមិនត្រូវនិយាយក្នុងកណ្តាលជំនុំទេ, សូមព្រះករុណាទ្រង់ជ្រាបថា: កាលណាពាក្យមួយមាត់ចូលទៅក្នុងត្រចៀកទាំង ៦ ពាក្យនោះមិននៅកំបាំងទេ, បើប្រសិនណាជាពាក្យនេះធ្លាក់ទៅក្នុងត្រចៀកទាំង ៤ ពាក្យនោះគ្មានអ្នកណាមួយព្រទេ, ចុះបើប្រសិនណាជាពាក្យនេះធ្លាក់ទៅក្នុងត្រចៀក ២, ពាក្យនោះ (Brahma) ព្រះព្រហ្មខ្លួនព្រះអង្គក៏មិនស្គាល់ដែរ, តើមនុស្សយើងចាំបាច់ឆ្ងល់អ្វី? ។

លុះស្តេចទ្រង់ព្រះសណ្តាប់ហើយ ព្រះអង្គនាំអ្នកចុតង្គទៅតែឯង រួចមានព្រះរាជឱង្ការថា: "ឱ! សទ្ធបុគ្គល (saint) គួរជាទីគោរព!

អ្នកបានឲ្យត្បូងឋអស់នេះមកខ្ញុំ ឯខ្ញុំគ្មានដែលបានឲ្យអ្នកបរិភោគក្នុងថ្ងៃណាមួយសោះ ខ្ញុំទោមនស្សណាស់ តើអ្នកចង់បានអ្វី?»

អ្នកធុតង្គទូលព្រះអង្គវិញថា: «បពិត្រព្រះមហាក្សត្រ នៅកន្លែងប៉ាធំមួយ នាមាត់ទន្លេគោទាវរី (Godavery) ខ្ញុំធ្វើសីល ហើយខ្ញុំសូត្រអាគមន៍គាថា ដែលខ្ញុំបានឈានតាំង៨, អាស្រ័យហេតុនេះទូលព្រះបង្គំសុំតែនៅជិតនឹងព្រះអង្គចំនួនមួយយប់ទេ, ដោយសារព្រះអង្គគង់នៅជិតនេះ សីលរបស់ទូលព្រះបង្គំនឹងបានសម្រេចមិនខាន» ។

ព្រះករុណាទ្រង់តបវិញថា: «មិនជាអ្វីទេ ចាំខ្ញុំត្រឡប់មកវិញ, ចូរអ្នកប្រាប់ខ្ញុំ តើថ្ងៃណាដែលខ្ញុំត្រូវទៅនៅជិតអ្នក?» ។

– សូមព្រះករុណាស្តេចយាងមករកខ្ញុំព្រះអង្គតែម្នាក់ឯង ហើយដាក់អាវុធមកផង ក្នុងយប់ថ្ងៃអង្គារ ១៤ កេច ខែសីហា ។

ព្រះករុណាមានព្រះរាជឱង្ការថា: «អ្នកអញ្ជើញទៅចុះ ខ្ញុំប្រាកដជាទៅម្នាក់ឯង» ។

អ្នកធុតង្គបានស្តាប់ព្រះទ័យព្រះមហាក្សត្រ ដោយពាក្យសន្យានេះរួចចូលទៅក្នុងវិហាររបស់លោក, លុះរៀបចំអស់គ្រឿងប្រដាប់ដែលលោកត្រូវការហើយ លោកក៏ទៅអង្គុយនៅទីប៉ាធាមួយ ។

លុះដល់កាលកំណត់ ព្រះមហាក្សត្រស្តេចចេញទៅតែមួយព្រះអង្គឯងកណ្តាលរាត្រី បានសៀតដាវនឹងព្រះអង្គទៅផង ដើម្បីទ្រង់

យាងទៅជិតអ្នកធុតង្គ ៗ លុះស្ដេចទៅដល់ អ្នកធុតង្គបានវន្ទាចំពោះទ្រង់ៗក៏គំនាប់អ្នកធុតង្គៗក្រាបទូលថា: "សូមទ្រង់គង់នៅទីនេះចុះ" ៗ ព្រះរាជាលុះទ្រង់គង់នៅទីនោះ ស្រាប់តែទតឃើញអារក្ស ខ្មោចព្រាយគ្រប់បែប ស្លៀកពាក់គួរឲ្យខ្លាច ចាំគ្រប់ទិស ៗ អ្នកធុតង្គដែលនៅអង្គុយចំកណ្ដាលហ្វូងបិសាចនោះក៏វាយឆ្អឹងក្បាលខ្មោចពីរ ៗ ព្រះមហាក្សត្រទ្រង់សណ្ឋិតនៅពីមុខទស្សនីយភាព (spectacle) នេះគ្មានញ័ររំភើបខ្លាចអ្វីសោះ បានទ្រង់សួរទៅអ្នកធុតង្គអំពីវត្ថុបំណងដែលចង់បានព្រះអង្គ ៗ អ្នកធុតង្គនិយាយថា: "បពិត្រព្រះមហាក្សត្រ! បើទ្រង់យាងមកយ៉ាងនេះហើយ សូមទ្រង់បំពេញព្រះរាជករណីយកិច្ចដូចខាងក្រោម: ចម្ងាយចំនួនពីរគីឡូម៉ែត្រអំពីទីនេះទៅខាងត្បូង មានប៉ាឆាមួយ ដែលមានខ្មោចមួយព្យួរនៅលើដើមឈើ សូមទ្រង់យកខ្មោចនោះមកឲ្យទូលព្រះបង្គំ ដើម្បីទូលព្រះបង្គំធ្វើតាមលំដាប់" ៗ ព្រះរាជាក៏ស្ដេចទៅត្រង់ទីនោះ ៗ អ្នកធុតង្គធ្វើព្រងើយ . ហើយតាំងបួញមាត់សូត្រធម៌ ៗ

យប់នោះជាយប់ងងឹតគួរឲ្យខ្លាចណាស់ ៗ ភ្លៀងធ្លាក់យ៉ាងខ្លាំងហាក់ដូចជាឈប់ភ្លៀងទៀតពីថ្ងៃនោះទៅ ឯខ្មោចនិងព្រាយផ្ដើមបណ្ដាលសូរសព្ទគួរស្ញែងខ្លាច ទោះបីអាទិទេពក្ដី វីរបុរស (héros) យ៉ាងក្លាហានក្ដី កាលបើឮដូច្នោះហើយ ក៏មិនអាចនឹងទប់ឃាត់នូវការភ័យញាប់ញ័រ

ឡើយ ៗ ប៉ុន្តែព្រះរាជាទ្រង់យាងទៅមិនមានតក់ស្លុត ៗ មានសត្វពស់លូនមកជិតរុំជុំវិញព្រះបាទ ព្រះអង្គទ្រង់ដេញវាចេញ ដោយបានសូត្រគាថាមួយ ៗ ព្រះមហាក្សត្រលុះចូលកាត់ព្រៃទាំងស្រួលទាំងលំបាកស្រេចហើយ ក៏បានស្តេចទៅដល់ប៉ាឆានោះ ហើយទ្រង់ឃើញអារក្សចាប់មនុស្សជាច្រើន យកមកវាយទាល់តែស្លាប់ ៗ ព្រះរាជាទ្រង់ទតឃើញព្រាយស៊ីប្រមាត់ពួកកូនក្មេង សត្វខ្លាឃ្មុំ ដំរីរោទ៍ ៗ លុះព្រះរាជាទ្រង់ទតឃើញដើមឈើហើយ ទើបពិនិត្យដោយហ្មត់ចត់ទៅឃើញថា: មែកនីមួយៗ ស្លឹកនីមួយ ៗ តាំងពីគល់ដល់ចុងមានភ្លើងឆេះយ៉ាងសន្ធោសន្ធៅ, គ្រប់ទិសទាំង ៤ លាន់ឮសូរស័ព្ទមិនឈប់ថា សម្លាប់! សម្លាប់! ចាប់វាមក ចាប់វាមក! ប្រយ័ត្នកុំឲ្យវារត់រួច? ៗ នៅពីមុខទស្សនីយភាពនេះ ព្រះមហាក្សត្រគ្មានញាប់ញ័របន្តិចទេ ប៉ុន្តែទ្រង់ព្រះតម្រិះថា: "ប្រហែលជាអ្នកធុតង្គស្រែកប្រាប់ព្រះអង្គទេដឹង?" លុះទ្រង់យាងទៅជិត ទ្រង់ទតឃើញខ្មោចមួយដែលចងដោយខ្សែពួរព្យួរក្បាលចុះមកដី ៗ.

ព្រះមហាក្សត្រទ្រង់មានព្រះទ័យសោមនស្ស ដោយទ្រង់ឃើញថាកំលាំងដែលព្រះអង្គខំស្តេចទៅនោះ បានសម្រេច ៗ ទ្រង់យកដាវនិងខែល យាងយ៉ាងរហ័សទៅលើដើមឈើ រួចហូតដាវនោះកាត់ខ្សែពួរ ឯរូបខ្មោចនោះក៏ធ្លាក់ចុះមកដល់ដីហើយទ្រហោយំ រួចខាំធ្មេញក្រឹត ៗ

ផង ។ ព្រះរាជាទ្រង់ទតឃើញដូច្នោះ ក៏មានព្រះទ័យសោមនស្ស ដោយទ្រង់ព្រះវិតក្កៈថាៈ មនុស្សនេះនៅរស់ទេ ។ ដល់ទ្រង់ចុះពីលើដើមឈើមកវិញទ្រង់សួរថាៈ "ឯងជាអ្នកណា ?" ។

ខ្មោចកាលបើឮដូច្នោះ ក៏តាំងស៊ើចក្អាកក្អាយ ដែលជាហេតុនាំឲ្យព្រះមហាក្សត្រធ្លាក់ពន់ពេក លុះស៊ើចហើយក៏ឡើងទៅលើដើមឈើព្យួរខ្លួនដូចមុនវិញ ។ ព្រះករុណាបានស្ដេចទៅតាមក្វាម ចាប់ដៃខ្មោចនោះនាំចុះមកដី ហើយមានព្រះរាជឱង្ការថាៈ "អាខ្មោច ! ប្រាប់អញមកមើល តើឯងជាអ្វី?" ។ តែទ្រង់គ្មានបានទទួលចម្លើយពីខ្មោចនោះវិញទេ ។ ទ្រង់ព្រះចិន្ដាថាៈ "ប្រហែលជាអ្នកលក់ប្រេង ដែលអារក្សនិយាយប្រាប់អញ ហើយដែលអ្នកធុតគ្គបានយកមកទុកក្នុងប៉ាធានេះទេដឹង !" ។ លុះទ្រង់ព្រះចិន្ដាឃើញដូច្នេះ ទើបទ្រង់រុំខ្មោចនោះក្នុងសំពត់ជរល្បាប់មួយ ហើយទ្រង់លីយកទៅ ។ អារក្សសួរព្រះអង្គវិញថាៈ "ឯងជាអ្នកណា ? រួចឯងនាំអញទៅណា ?" ។ ព្រះរាជាទ្រង់តបវិញថាៈ "យើងជាស្ដេចពិករ័ន (Bik ran) យើងនាំអ្នកទៅរកអ្នកធុតគ្គ" ។ អារក្សឆ្លើយវិញថាៈ "ទូលព្រះបង្គំទៅបាន ប៉ុន្តែទូលព្រះបង្គំសុំអនុញ្ញាត ១ ។ គឺសូមកុំឲ្យទ្រង់មានព្រះរាជឱង្ការ ក្នុងពេលកំពុងស្ដេចទៅ, បើប្រសិនជាមានព្រះរាជឱង្ការ ទូលព្រះបង្គំនឹងត្រឡប់ទៅដើមឈើរបស់ទូលព្រះបង្គំវិញ" ។ (មានត)

# ដំណើរមកកាន់ប្រទេសកម្ពុជា

## នៃមហាបណ្ឌិត គុណបាលពិយសេន ម៉ាល៉ាល័ៈសេកេរៈ

### ជាអធិបតីពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប

## របស់ពុទ្ធសាសនបណ្ឌិត្យ

(តមក)

---

បន្ទាប់មកលោកម៉ាល៉ាល័ៈសេកេរៈ បានថ្លែងសុន្ទរកថាឥតព្រាងមួយតបវិញជាភាសាបាឡី, សេចក្ដីនៃសុន្ទរកថានោះដូច្នេះ ថា

អស់លោកអ្នកទាំងឡាយ! ខ្ញុំសូមថ្លែងអំណរគុណដល់សមាគមមិត្តសាលាបាឡី ដែលបានជូនកិត្តិយសដល់ខ្លួនខ្ញុំដោយការទទួលយ៉ាងអឹកធឹកនេះ ។ ខ្ញុំមានសេចក្ដីព្រឺព្រួចក្នុងចិត្តពន់ពេក ដោយការបានដឹងអំបាញ់មិញថា ការសិក្សាពុទ្ធសាសនានៅប្រទេសកម្ពុជា មានសាលារៀនយ៉ាងក្រាស់ក្រែលដែលនៅក្នុងការឧបត្ថម្ភនៃរាជការ ហើយមានព្រះសង្ឃចេះដឹងជ្រៅជ្រះជាច្រើន ទាំងជាអ្នកប្រតិបត្តិយ៉ាងតឹងរឹងតាមព្រះវិន័យ; ប៉ុន្តែខ្ញុំមានអំណរជាទីបំផុតនោះ ត្រង់ដែលថាប្រទេសកម្ពុជាបំរុងនឹងបង្កើតពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគ មានសហការជាប់នឹងពុទ្ធិកសមាគមពិភពលោក ដែលមានទីសំណាក់ការតាំងនៅលង្កាទ្វីបសព្វថ្ងៃនេះ ។ កិច្ចនេះហើយដែលអាចញុំាងសាមគ្គីធម៌ឲ្យកើតមានរវាងប្រទេសកាន់ពុទ្ធសាសនាទាំងឡាយ ហើយជាកំឡាំងមួយយ៉ាងធំ ដែល

អាចនឹងនាំយើងឲ្យបង្កើតក្រុមបេសកកម្មខាងផ្សាយសាសនា ដូចជាពួកសាសនាគ្រិស្តធ្លាប់បំពេញមកនោះបាន ។

ចំណែកការប្រែស្រ័យទាក់ទងគ្នា ក្នុងផ្លូវសាសនារវាងប្រទេសកម្ពុជានឹងលង្កាទ្វីបនេះ សឹងមានវែងឆ្ងាយនៅក្នុងប្រវត្តិសាស្ត្រថាមានជាយូរអង្វែងមកហើយ ។ ក្រោយដែលប្រទេសកម្ពុជាបានទទួលព្រះត្រៃបិដកជាភាសាបាលី ដែលជារបស់ថេរវាទ រួចយកអំពីសំណៅព្រះបាទអនុរុធមហារាជ (ព្រះចៅធៀងម៉ៃ) ដែលចម្លងពីលង្កាទ្វីប ហើយសំណៅនោះមកកៀងនៅប្រទេសខ្មែរនេះ ។ ព្រះបាទសុរិយវរ្ម័នទីពីរ ក៏បានបញ្ជូនព្រះសង្ឃខ្មែរ ៨ រូប; ក្នុងចំនួននេះ មានព្រះរាជបុត្រជាទីស្រឡាញ់ប្រាណរបស់ព្រះអង្គ ១ អង្គផង ដែលមានព្រះនាមឆាយាថា ញាណសិទ្ធិ ។ ព្រះសង្ឃទាំង ៨ រូបនេះ បានបួសប្រែងជាថ្មីទៀតនៅលង្កាទ្វីប ព្រោះពេលនោះប្រទេសកម្ពុជា មានសុទ្ធតែពួកមហាយាន ដែលចេះតែភាសាសំស្ក្រឹត ។ ព្រះសង្ឃទាំង ៨ រូបនេះ បានទៅសិក្សាភាសាបាលីនិងវិជ្ជាផ្សេងៗ ជាយូរឆ្នាំនៅមហាវិទ្យាល័យពុទ្ធសាសនា នៃវត្តមហាវិហារក្នុងអនុរាធបុរៈ ។ លុះសិក្សាបានចេះដឹងសព្វគ្រប់ហើយ លោកនិមន្តត្រឡប់មកផ្សាយសាសនានៅប្រទេសកម្ពុជាវិញ ដរាបដល់បានជ័យជំនះលើពួកមហាយាន ។ វត្តមហាវិហារនេះហើយ ដែលភិក្ខុហ្វាហៀនជាសមណទូតចិនបានទៅនៅសិក្សាអស់ពេលដ៏យូរ ។ រឿង

នេះ មិនមែនមានតែក្នុងប្រទេសលង្កាទេ គឺមានសេចក្ដីពិស្ដារនៅក្នុងចារឹកកល្យាណីនៃប្រទេសភូមាផង ។

ដើម្បីនឹងសើរើរបៀបទាក់ទងគ្នាដោយការសិក្សានេះឡើងវិញ រដ្ឋាភិបាលលង្កាមានបំណងនឹងបង្កើត មហាវិទ្យាល័យពុទ្ធសាសនាមួយនៅលង្កាទ្វីប សំរាប់ទទួលសិស្សមកពីប្រទេសនានា ៗ សាលានុះមានគោលបំណងយ៉ាងធំ សំរាប់អប់រំព្រះសង្ឃឲ្យធ្វើជាគណាចារ្យក្នុងការផ្សាយសាសនាទៅនានាប្រទេស ។ បើប្រសិនជាសាលានេះបានកើតឡើងដូចបំណងហើយ នោះមុខជាព្រមទទួលឲ្យព្រះសង្ឃពីប្រទេសកម្ពុជាទៅសិក្សាផងជាពុំខាន ។

បងប្អូនពុទ្ធសាសនាទាំងឡាយ! យើងពួកពុទ្ធសាសនាគួរខ្មាសពួកសាសនាជាតិដទៃណាស់ ព្រោះគេហ៊ានស៊ូប្ដូរជីវិត ក្នុងការបំពេញបេសកកម្មផ្សាយសាសនា ដូចយ៉ាងការផ្សាយសាសនាគ្រិស្ដនៅអាហ្វ្រិក ដែលសុទ្ធតែជាជាតិកាចសាហាវ សឹងមានគណាចារ្យខ្លះបានទទួលគ្រោះ ត្រូវពួកនេះសម្លាប់ ។

ចំពោះពុទ្ធសាសនាយើងវិញ កាលពីដើមមានអ្នកកាន់តិចទេ តែឥឡូវនេះ មានប្រទេសដល់ទៅ ២៨ បានរាប់អាននោះ ក៏មកពីគណាចារ្យបុរាណ ដែលមានមហាវិទ្យាល័យនៅលន្ទា (ឥណ្ឌា) និងមហាវិទ្យាល័យមហាវិហារជាអ្នកបង្កើត ហើយនឹងក្រុមគណាចារ្យ

បច្ចុប្បន្នដែលមានប្រទេសលង្កាជាអ្នកខ្នះខ្នែងបំផុត ។ ការដែលពុទ្ធ-សាសនាយើងក្រីក្រទៅនេះ មិនមែនមកពីខ្វះអ្នកជឿទេ គឺខ្វះគណាចារ្យដែលមានសមត្ថភាពនិងខ្វះធនធាន ។ ដូច្នេះហើយបានជាយើងត្រូវតែចងបាច់គ្នាយ៉ាងធំ ដើម្បីនឹងផ្សាយពុទ្ធសាសនារបស់យើងទៅឲ្យប្រទេសអឺរុបនឹងប្រទេសដទៃទៀត ដែលគេផ្សាយសាសនារបស់គេមកឲ្យយើង ជាកិច្ចតបស្នងទៅគេវិញផង ។

ដើម្បីនឹងញ៉ាំងផែនការណ៍នេះឲ្យសម្រេចទៅបាន ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមាំ លើសេចក្តីខ្វល់ខ្វាយនៃសមាគមមិត្តសាលាបាលីនឹងកិច្ចសិក្សានៃព្រះសង្ឃ ដែលខ្ញុំបានឃើញនៅសាលាបាលីជាន់ខ្ពស់នេះ ។ ប៉ុន្តែខ្ញុំសូមរំឭកថា : ដើម្បីនឹងធ្វើជាអ្នកប្រកាសផ្សាយសាសនានោះ គេមិនមែនរៀនតែភាសាបាលី សំស្ក្រឹតនឹងព្រះត្រៃបិដកប៉ុណ្ណោះទេ គឺត្រូវរៀនភាសាណាដែលគេនិយមប្រើក្នុងលោក វិទ្យាសាស្ត្រផ្សេងៗ នឹងលទ្ធិសាសនាគេឬទំនៀមទម្លាប់ស្រុកទេសគេផង ព្រោះថាបើយើងមិនចេះសាសនាគេឬទំនៀមទម្លាប់ស្រុកគេទេ យើងក៏មិនអាចនឹងទៅប្រដៅគេបានឡើយ ។

ចំពោះបេសកកម្មរបស់ខ្ញុំក្នុងពេលនេះ ខ្ញុំគ្មានបំណងអ្វីក្រៅពីយកទង់សាសនាទៅជូនប្រទេសដែលកាន់ពុទ្ធសាសនា ដើម្បីសុំឲ្យប្រកាសប្រើជាផ្លូវការ ហើយនឹងការក្រែនពុទ្ធបរិស័ទឲ្យសាមគ្គីគ្នា លែងប្រ

កាន់និកាយ ដើម្បីនឹងផ្សាយសាសនា សុំឲ្យប្រទេសទាំងឡាយ តាំងពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគឡើង ប្រយោជន៍នឹងជួយផ្ទប់កម្លាំងគ្នា ។ សូមអស់លោកខេមរជាតិជ្រាបថា: ក្នុងថ្ងៃនេះជាឱកាសធ្វើពិធីបុណ្យវិសាខបូជា, ប្រទេសកាន់ពុទ្ធសាសនាទាំងឡាយ នឹងលើកទង់សាសនាថ្មីនុះ ក្នុងថ្ងៃនេះព្រមគ្នា សូម្បីប្រទេសជប៉ុនដែលកាលពីដើមមក ពុំដែលធ្វើវិសាខបូជាសោះ ក៏ក្នុងពេលនេះនឹងធ្វើពិធីនេះដែរ ” ។

មហាបណ្ឌិតបានបញ្ចប់សុន្ទរកថានេះ ដោយថ្លែងអំណរជាថ្មីទៀតដល់លោកអ្នកស្តាប់ទាំងឡាយដែលបានជូនឱកាសយ៉ាងវែងឲ្យលោក ។

ក្នុងពេលដែលលោកអញ្ជើញមកទស្សនាការនេះ ពុទ្ធសាសនបណ្ឌិត្យ, សាលាបាលីជាន់ខ្ពស់ នឹងសមាគមមិត្តសាលាបាលី បានជូនសៀវភៅផ្សេងៗ ដល់លោកដើម្បីទុកជាទីរឭក ។

## លោកម៉ាល៉ាល់:សេកេរ:ចូលមើល
## ពិពិធភណ្ឌអាលប៊ែរសារ៉ូត៍ និង សាលារចនា

កាលពីថ្ងៃសៅរ៍ទី ១៩ ខែឧសភា នៅពេលម៉ោង ៨ នឹង ៣០ នាទី លោកម៉ាល៉ាល់:សេកេរ: បានអញ្ជើញទៅមើលមន្ទីរពិពិធភណ្ឌ “អាល់ប៊ែរសារ៉ូត៍” នឹងសាលារចនា ដោយមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងសិក្សាធិការនឹងសិល្បការរង់ចាំទទួល ។ មហាបណ្ឌិតបានពិនិត្យ

បុរាណវត្ថុរបស់យើងយ៉ាងជាប់ចិត្ត ,  រួចលោកអញ្ជើញទៅមើលសាលារចនា ៗ ក្នុងពេលនោះសិស្សគ្រប់ផ្នែកកំពុងតែផ្ចិតផ្ចង់មេរៀនរៀងខ្លួន ៗ នៅទីនេះ  មហាបណ្ឌិតមានប្រសាសន៍ពាក្យសន្ទិបាត  ជាពាក្យមានទំនងដូចជាឧត្តមគតិនៃមហាត្មៈគន្ធីថា:  "យើងអ្នកកាន់ពុទ្ធសាសនាគួរតែតែនាំគ្នាធ្វើសំពត់ប្រើប្រាស់ដោយខ្លួនយើង  មិនគួរយើងលក់សំឡីសូត្រដែលយើងធ្វើបាន  ដោយលំបាកកាយយ៉ាងខ្លាំងនោះទៅ ឲ្យគេយ៉ាងថោកៗ ដល់គេធ្វើជាសំពត់យកមកលក់ឲ្យយើងវិញយ៉ាងថ្លៃ ៗនោះទេ" ៗ

នៅពេលនោះ  លោករដ្ឋមន្ត្រីបានជូនទុកជាទីរឭកដល់ភ្ញៀវនេះនូវវត្ថុរចនាជាច្រើនមុខ  គឺខ្សែកប្រាក់ក្បាច់ផ្លែក្រចៅ ១, ខ្សែ ២, ឡេវដៃអាវបញ្ចុះថ្នាំ ២, កន្ទាស់ក ១ សុទ្ធតែធ្វើអំពីប្រាក់  ដែលប្រទេសលង្ការាប់អានថាជារបស់មានដំឡៃលើសជាងមាស  ហើយនឹងសំពត់ហូល ២ ដែលត្បាញជាព្រះពុទ្ធរូបសំរាប់តាំង ៗ

## លោកម៉ាល៉ាល៉ះសេកេរៈ ទស្សនាវិទ្យាល័យស៊ីសុវត្ថិ

បន្ទាប់មក  មហាបណ្ឌិតនេះបានអញ្ជើញទៅទស្សនាវិទ្យាល័យស៊ីសុវត្ថិ ៗ វេលានោះ សិស្សទាំងឡាយនឹងគ្រូបារាំង - ខ្មែរ ច្រើនរយនាក់កំពុងឈរព័ទ្ធជើងទង់ ៗ  លុះបានធ្វើពិធីលើកទង់ជាតិដោយមានច្រៀងបទនគររាជរួចហើយ  មានសិស្សម្នាក់បានថ្លែងសុន្ទរកថាមួយជាភាសាខ្មែររំឭកអំពីមេត្រីភាពខាងផ្លូវសាសនាដែលប្រទេសកម្ពុជា នឹងប្រទេសលង្កា

ធ្លាប់ធ្វើមកជាមួយគ្នាតាំងពីបុរាណកាល ហើយនឹងបញ្ជាក់ឲ្យឃើញអំពីសេចក្ដីគោរពចំពោះពុទ្ធសាសនារបស់ពួកសិស្ស ដោយមានការធ្វើកឋិននឹងវិសាខបូជាជាដើមតាមប្រពៃណី ។ សុន្ទរកថានេះបានបញ្ចប់ដោយជូនសព្ទសាធុការពរ ដល់កៀវនេះ ហើយលោកញ៉ុក-ថែមបានប្រែជាភាសាបាលី ។

លោកម៉ាល់ៈសេកេរៈ បានថ្លែងសុន្ទរកថាឥតព្រាងមួយវិញ ជាភាសាបាលី ។ សេចក្ដីសង្ខេបនៃសុន្ទរកថានោះថា : សុំឲ្យគ្រូនឹងសិស្សទាំងឡាយសើរើយកមេត្រីភាព ដែលប្រទេសទាំងពីរនេះធ្លាប់មាននឹងគ្នាកាលពីដើមនោះមកឡើងវិញ ។ លោកបានបញ្ជាក់ថា : ការសិក្សាដែលមានសេចក្ដីគោរពយ៉ាងមាំ ក្នុងសេចក្ដីស្នេហាជាតិនេះហើយ ដែលអាចជូនផលមកឲ្យប្រទេសជាតិខ្លួនបាន ។ ឯវត្ថុបំណងយ៉ាងមាំធំបំផុតក្នុងបេសកកម្មរបស់ខ្ញុំ គឺការបបួលប្រទេសកាន់ពុទ្ធសាសនាទាំងឡាយឲ្យរួបរួមគ្នាលែងប្រកាន់ពួកគណៈហីនយានឬមហាយាន ដើម្បីនឹងទៅជាប័ក្ខព័ន្ធមួយដែលមានតេជានុភាពយ៉ាងធំបំផុតក្នុងអនាគត ។ ប្រទេសកាន់ពុទ្ធសាសនាទាំងឡាយ ដែលបានធ្លាក់ទៅក្នុងសេចក្ដីថោកទាបជាច្រើនរយឆ្នាំមក ហើយដែលគួរឲ្យមានសេចក្ដីខ្មាសជាទីបំផុតនេះ មកតែអំពីការមិនចេះបងបាច់គ្នា ដូច្នេះយើងត្រូវតែឈមមុខទៅរកសាមគ្គីដែលមានខ្លឹមសារនោះ មិនត្រូវរួញរាឲ្យសោះ" ។

ក្នុងសន្និបាតនេះ  កាលមហាបណ្ឌិតថ្លែងជាភាសាបាលីរួចហើយ តមកលោកថ្លែងជាភាសាអង់គ្លេសទៀត ដោយមានលោកក្រុមង៉ុយបកប្រែជាភាសាបារាំង ។

## លោកម៉ាឡាឡ័ះសេកេរៈទស្សនាអនុវិទ្យាល័យនារី

ក្នុងថ្ងៃដដែលនេះ លោកម៉ាឡាឡ័ះសេកេរៈ បានបន្តដំណើរទៅទស្សនាអនុវិទ្យាល័យនារីទៀត  ដែលមានលោកស្រីបរណេជាចាង-ហ្វាងសាលានេះនៅចាំទទួល ។ សិស្សនារីយើងចំនួន ១៥០ នាក់បានស្លៀកពាក់ឯកសណ្ឋានជាគ្រឿងសំគាល់សាលា ចាំទទួលលោក ។ លោកម៉ាឡាឡ័ះសេកេរៈបានសួរអំពីកម្មវិធីនៃការបង្រៀន, អំពីអត្ត-ពលកម្មនឹងស៊ីវិល្យអ៊ូខ្លះដែលមាននៅក្នុងសាលានេះ ។ ដោយឃើញចំនួនស្រីខ្មែរដែលសិក្សានៅសាលាជាន់ខ្ពស់នេះតិចពេក, លោកក៏លាន់មាត់សួរលោកស្រីចាងហ្វាង ។ លោកស្រីបានតបថា ពួកស្រីខ្មែរទើបតែផ្តើមស្រឡាញ់ការសិក្សាទេ  ហើយច្រើនតែចូលចិត្តឈប់រៀនក្នុងពេលដែលប្រឡងបានសញ្ញាបត្របឋមសិក្សាបារាំងខ្មែរ ។ ត្រង់នេះ មហាបណ្ឌិតបានឆ្លៀតអួតថា នៅស្រុកលោក មានស្រីរៀននៅមហាវិទ្យាល័យដល់ទៅជាងពីរពាន់នាក់ ។

## លោកម៉ាឡាឡ័ះសេកេរៈធ្វើសន្និសីទនៅព្រះកែវមរកត

នៅម៉ោង ១៧ នៃថ្ងៃនោះ  មហាបណ្ឌិតបានធ្វើសន្និសីទនៅមន្ទីរព្រះ

សទ្ធម្មនៃវត្តព្រះកែវមរកត ។ ក្នុងមហាសន្និបាតនេះមានព្រះសង្ឃគណៈមហានិកាយ-ធម្មយុត្តិ និងពួកគ្រហស្ថប្រុសស្រីខ្មែរក្តីចិនយួនចំនួនប្រហែលជាង ៦.០០១ នាក់ ។ ក្នុងពិធីនេះ ឯកឧត្តមសមញ្ញាណបានអញ្ជើញទៅជាអធិបតី ជាមួយនឹងសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ សម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា ល្វី-ឯម និងព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ។

លុះជួបជុំហើយ មហាបណ្ឌិតបានថ្លែងសុន្ទរកថាជាភាសាបាលី ដោយមានព្រះគ្រូសំសត្ថាប៉ុណ្ណ-សម្ភាជ ជាអ្នកបកប្រែ ដូចមានសេចក្តីដែលយើងសរសេរសម្រួលតទៅនេះ :-

បពិត្រលោកដ៏ចំរើនទាំងឡាយ !

ខ្ញុំមានចិត្តត្រេកអរណាស់ ដែលបានទទួលកិត្តិយសយ៉ាងខ្ពង់ខ្ពស់ក្នុងការសំដែងបាឋកថាជាឧឡារិក ដែលមានព្រះតេជព្រះគុណគប់ព្រះអង្គនឹងលោកអ្នកសប្បុរសទាំងឡាយ មកជួបជុំជាចំនួនច្រើនយ៉ាងនេះ ។ ខ្ញុំស្មានខុសថាសេចក្តីរុងរឿងនៃពុទ្ធសាសនានៅប្រទេសកម្ពុជា មុខជាមិនប្រសើរដល់ថ្នាក់នេះទេ ប៉ុន្តែដំណើរទស្សនាការរបស់ខ្ញុំនេះ បានបន្ទេចពស្តុតាងឲ្យឃើញជាក់ច្បាស់ថាគ្មានប្រទេសកាន់ពុទ្ធសាសនាណាមួយក្នុងលោក ថ្លៃថ្នូរដូចជាប្រទេសនេះឡើយ គឺប្រទេសកម្ពុជាមានពុទ្ធ

បដិមាមាសសុទ្ធយ៉ាងធំៗ ដែលខ្ញុំទើបនឹងឃើញអំបាញ់មិញនៅក្នុងព្រះវិហារនៃអារាមនេះ ហើយដែលខ្ញុំមិនធ្លាប់ជួបប្រទះនៅក្នុងប្រទេសណាសោះ ៗ ខ្ញុំបានឃើញកិច្ចការយ៉ាងសំខាន់ៗ ដទៃទៀតជាច្រើន ដូចជាកិច្ចការនៃក្រុមជំនុំប្រែព្រះត្រៃបិដក ដែលប្រទេសណាមួយមិនទាន់មានសោះ ហើយនឹងកិច្ចការរៀនសូត្រខាងផ្លូវសាសនា ដែលមានសាលាបាលីជាន់ខ្ពស់, សាលាបាលីរងនឹងសាលាធម្មវិន័យ នៅក្នុងកិច្ចចាត់ការយ៉ាងប៉ិនប្រសប់នៃរដ្ឋាភិបាល ៗ អំពីសេចក្ដីរាក់ទាក់វិញ ខ្ញុំគ្មានឃើញប្រទេសណាមួយដែលខ្ញុំធ្វើដំណើរឆ្លងកាត់មកលើកនេះ ដូចកិត្តិយសដល់ខ្ញុំដែលជាធម្មទូតនៃសមាគមពិភពលោក ដែលហៅ "លោកពុទ្ធសម្មេលនៈ" ដូចជាប្រទេសកម្ពុជានេះទេ គឺនៅទីកន្លែងណាក៏ដោយប្រជាជនតែងមានមុខញញឹម ហើយទទួលយ៉ាងអ៊ឹកអធឹក ៗ

ចំណែកសេចក្ដីប្រតិបត្តិនៃព្រះសង្ឃក៏ឃើញថាមានរបៀបរៀបរយណាស់ដែរ ព្រោះនៅតាមផ្សារ ខ្ញុំមិនសូវឃើញព្រះសង្ឃនិមន្តរហេតរហូតទេ ហើយការឆាន់កាហ្វេដោយកៀមចិន ក៏ខ្ញុំមិនជួបប្រទះ ដូចជានៅប្រទេសខ្លះ ដែលខ្ញុំបានដើរកាត់មកនោះឡើយ ៗ ដូច្នេះ ពុទ្ធសាសនានៅប្រទេសកម្ពុជាចាត់ថាមាន សេចក្ដីរុងរឿងជាបំផុត ដោយមានព្រះមហាក្សត្រទ្រង់ជាអគ្គសាសនូបត្ថម្ភ ៗ

លោកអ្នកសប្បុរសទាំងឡាយ ប្រហែលជានឹកឆ្ងល់នឹងបេសកកម្មរបស់ខ្ញុំនេះខ្លះដែរដឹង! ប៉ុន្តែបើលោក-អ្នកបានជ្រាបអំពីដំណើរសន្និសីទ

ពុទ្ធសាសនានៅលង្កាទ្វីប ដែលសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក បានទទួលកិត្តិយសជាប្រធាននោះ មុខជានឹងបាត់ឆ្ងល់ពុំខាន ។ ខ្ញុំគ្មានប្រាថ្នាអ្វីក្រៅអំពីសុំក្រែនប្រទេសពុទ្ធសាសនាទាំងឡាយ ឲ្យរួបរួមគ្នាក្នុងការបង្កើនកម្លាំងសមាគមពិភពលោក ដែលសព្វថ្ងៃនេះមានជាស្រេចទៅហើយនៅប្រទេសលង្កានោះទេ គឺសុំឲ្យពួកពុទ្ធសាសនិកជនគ្រប់និកាយ ទោះជាមហាយានក្តី ហីនយានក្តី រួបរួមកម្លាំងគ្នាបង្កើតជាពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគឡើង ដែលហៅថា "សាខាសាមីតិ" ដែលត្រូវមានកិច្ចទាក់ទងនឹងពុទ្ធិកសមាគមពិភពលោកនោះ ។ ការធ្វើដូច្នោះ គឺដើម្បីនឹងបំពេញបេសកកម្មក្នុងការផ្សាយពុទ្ធសាសនា ទៅនានាប្រទេស ។ ប៉ុន្តែដែលនឹងធ្វើដូច្នេះបាន លុះណាតែយើងបង្កើតការសិក្សា សម្រាប់ព្រះសង្ឃឲ្យបានមាំមួនសិន ដែលត្រូវតែបង្កើតមហាវិទ្យាល័យពុទ្ធសាសនាមួយ នៅប្រទេសលង្កាសំរាប់អប់រំគណាចារ្យ ។ រដ្ឋបាលលង្កាបានព្រមឲ្យបង្កើតសាលានេះ, សមាគមពិភពលោកនឹងទទួលទំនុកបំរុងយ៉ាងមុតមាំនូវសាលានេះ ព្រមទាំងទទួលសិស្សពីប្រទេសនានាមានប្រទេសកម្ពុជាជាដើមឲ្យទៅរៀនផង ។

លោកអ្នកសប្បុរសទាំងឡាយ ! ក្នុងសម័យបុរាណ ប្រទេសកម្ពុជា ធ្លាប់មានសម្ពន្ធកិច្ចខាងផ្លូវសាសនា យ៉ាងជិតស្និទ្ធនឹងប្រទេសលង្កា ។ មានព្រះសង្ឃខ្មែរច្រើនរូប បានទៅរៀននៅមហាវិទ្យាល័យ

មហាវិហារក្នុងអនុរាធៈបុរី ដើម្បីចំឡងយកលទ្ធិហីនយាន ។ ប៉ុន្តែដល់ក្រោយមក កិច្ចទាក់ទងនោះក៏បានបាត់បង់អស់ទៅវិញ ដោយសារប្រទេសយើងទាំងពីរធ្លាក់ទៅក្នុងអាណាព្យាបាលប្រទេសដទៃ ។ សូម្បីដូច្នោះ ការប្រស្រ័យគ្នាខាងសមណទូត ក៏នៅតែមានទៅវិញទៅមកដរាបដល់មុនសង្គ្រាមលោកលើកទីពីរនេះ កស្តុតាងដូចមានព្រះសង្ឃលង្កានាំយកព្រះពោធិព្រឹក្សនឹងព្រះសារីរិកធាតុ មកប្រតិស្ឋាននៅប្រទេសកម្ពុជាជាដើម ។

សូមអស់លោកអ្នកជ្រាប: នៅប្រទេសលង្កា មានគម្ពីរស្លឹករឹតជាអក្សរខ្មែរ ដែលគេដំកល់ទុកយ៉ាងប្រពៃ ។ អ្នកលង្កាដែលចេះភាសាបាលី ច្រើនតែនិយមរៀនអក្សរខ្មែរដែរ គ្រាន់នឹងមើលគម្ពីរទាំងនោះ ។ ចំណែកខ្លួនខ្ញុំក៏អាចមើលអក្សរខ្មែរជាភាសាបាលីបានដែរ ។ ដូច្នេះឃើញថា មេត្រីភាពនៃប្រទេសយើងទាំងពីរ ដែលបាត់បង់ទៅជាយូរហើយនោះ ហាក់ដូចជាមានជីវភាពដរាបដល់សព្វថ្ងៃនេះ ។

អស់លោកទាំងឡាយ ! ខ្ញុំមានសេចក្តីត្រេកអរណាស់ ដែលបានឃើញមេត្រីភាពខាងសាសនានេះ មានរូបកាងឡើងវិញ ក្នុងពេលដែលខ្ញុំចូលក្រាបថ្វាយបង្គំព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដើម្បីថ្វាយទង់សាសនា ហើយបានទទួលព្រះបដិសណ្ឋារ យ៉ាងខ្ពង់ខ្ពស់បំផុត ។ ទង់សាសនានេះ គឺមហាសន្និបាតពុទ្ធសាសនា ដែលមានប្រទេស

កម្ពុជាជាសមាជិកដែរនោះ បានសម្រេចយល់ព្រម ហើយប្រទេសទាំងឡាយដែលកាន់ពុទ្ធសាសនាចំនួន ៦៤ ប្រទេស នឹងលើកទង់នេះប្រើព្រមគ្នាក្នុងថ្ងៃវិសាខបូជានេះផង ។

ខ្ញុំសូមរំឭកអស់លោក - អ្នកជាពុទ្ធបរិស័ទទាំងឡាយ, សូមអស់លោកយកចិត្តទុកដាក់ក្នុងការផ្សាយសាសនាទៅនានាប្រទេស ព្រោះព្រះធម៌វិន័យរបស់ព្រះពុទ្ធម្ចាស់ ជារបស់កណ្តាល មិនមែនប្រដៅចំពោះតែប្រទេសណាមួយ ឬចំពោះតែបុគ្គលណាមួយទេ ។ មួយទៀតព្រះធម៌នោះជារបស់មិនចេះស្លាប់ មិនចេះហួសសម័យ ហើយជាទីមនោរម្យនៃសត្វទាំងពួង ។

សូមអស់លោកទាំងឡាយ បណ្តុះសាមគ្គីធម៌ លះបង់មានះ កុំប្រកាន់ពួក កុំប្រកាន់និកាយ ព្រោះយើងជាកូននៃព្រះពុទ្ធតែមួយព្រះអង្គ ដែលយើងត្រូវជាបងប្អូនបង្កើតនឹងគ្នាខាងផ្លូវចិត្ត ក្នុងការប្រតិបត្តិព្រះធម៌ ដែលចេញមកពីព្រះឱស្ឋរបស់ព្រះពុទ្ធតែមួយអង្គដែរ ។

អស់លោកទាំងឡាយ ! កាលសម្តេចព្រះមហាសុមេធាធិបតី និមន្តទៅលង្កាទ្វីបនោះ ប្រជាជនលង្កាមានសេចក្តីសរសើរនឹងសេចក្តីជ្រះថ្លារាប់អានគ្រប់គ្នា ។

(មានត)